T. VII / Koeung' Neang Champathong R.62-4-58
B-14


# រឿងនាងចំប៉ាថោងឡឿ ៧



ទ-ទ
111

ARCHIVES NATIONALES



ព្រះនាងក្សាក្សាក់ ព្រះស្មាតដាក់ ទើបព្រះកុមារ
នានាំព្រះមេ ទៅឯព្រះពន្លា នាងចំយាត្រា
ទីងបុត្រកល្យាណា ៗ ឯក្រុងយក្សា ស្តេចហោះដល់ប្រា
សាទសួគ៌វិមាន យល់បុត្របែសារ ចោះណាក្សត្រក្សាន
ថ្មមទិបបីបាន ទ្រង់ព្រះសោកា ៗ ហើយស្តេចត្រកង
ព្រះសប់សួនត្រង ចុះមកពន្លា ដំកល់ទុកស្រេច
សម្តេចក្សត្រា កិលាកក្តាត់ណា តតងមានស្បើយ ៗ
រីកដជាយា ទីងពង្សពុន្លា ដល់ពុំលុងឡើយ
ទិបព្រះបាទា ព្រះមហាក្សត្រហើយ ដួលដេកកៀកកើយ
សន្ទប់លុងក្រៃ ៗ សំស្រិតទាសា យកព្រះគង្គា
កៀតព្រះកក្តៃថ្ង ព្រះនាងក្សាក្សាក់ ជីងព្រះស្មារតី
អួលអាណាតក្រៃ សោយសោកយោបំ ៗ អស់ទុក្ខធរ
ស្តែងស្តេចចាកបរ មកមិនយល់ខ្ញុំ ខ្ញុំព្រាត់ព្រះមហា
ក្សត្រាឧត្តម ខ្ញុំរង់ទុក្ខធំ ឆ្នាំបីហើយណា ៗ
កាលស្តេចមកដល់ ប្អូនសោតអរសល់ ស្មានបានជួបគ្នា
ម្តេចឡើយវិងឃ្លាត ព្រះបាទព្រះមហា គម្តែងក្រឡា
លុះលះលោកចេញ ៗ អស់ទិព្រះបង យកខ្ញុំទៅផង
ព្រមព្រះសំឡាញ់ ទុកប្អូនឲ្យនៅ ប្អូនក្តៅប្អូនម្ចេញ
ពង់ពោះពោពេញ សង្រែងសោកក្រៃ ៗ ទិព្រះមិត្តមាស

បើនឹងប្រែប្រាស　　ចាកចេញទីទៃ　　បានផ្ដែផ្ដាំក៏
សិនសឹមនឹងក្បៃ　　ក្បៃម្ដេចឡេះនៃ　　សូទ្យអាណោថា ៗ
ម្ដេចឡើយព្រះអង្គ　　ពិសេសពុំទ្រង់　　ព្រះរាជករុណា
បុត្រាសនាងខ្ញុំ　　ទើបពុំនាំពា　　ពុំប្រែកត្រា
ត្រង់ប្អូនឡើយហោង ៗ　　ព្រះសើយប្អូនណើ　　ខ្ញុំប្អូននេះលើ
ព្រះបាទព្រះបង់　　ផ្សិតប្អូនកំព្រា　　ឥតគ្នាពីរផង
បាបអ្វីនេះម្ដង　　ព្រោះត្រាស់ទៀតទៅ ៗ　　ឪទ្រង់បង្អៀត
សូវស្លាប់បង់សៀត　　មួលមួយព្រះថៅ　　រីឯត្រង់រស់
ជាមនុស្សហើយហៅ　　មេម៉ាយអាសៅ　　អាសោចឥតការ ៗ
រស់នៅទ្រមឹង　　ព្រះមាសព្រលឹង　　ចាកចោលឃ្លាតឃ្លា
រស់មិញស្មើស្លាប់　　អាកពាប្រើនត្រា　　ខ្ញុំពុំប្រាថ្នា
រស់រួចឡើយហោង ៗ　　ព្រះសើយប្អូនគិត　　ប្អូនរងអាណិត
ព្រះបាទព្រះបង់　　អាសូរស័យា　　យាត្រាមកផ្គង់
ស្ថានទឹងដូចប៉ង　　កៀមកក្រ្ដសុខា ៗ　　អម្ចាស់ប្អូនអើយ
អ្នកសុគត់ហើយ　　រាប់ចុំរាប់ថ្ងា　　ខ្ញុំចាំតែឈ្មោះ
សូន្យសោះរូប៉ា　　ពុំយល់កក្រ្ដា　　ពីថ្ងៃនេះម្ដង ៗ
ឱព្រះម្ចាស់ខ្ញុំ　　ខ្ញុំសោកខ្ញុំយំ　　ផ្សាខ្លោចកន្លង
ម្ដេចផ្ដុំកន្ដើយ　　ព្រះអើយឡេះហោង　　ខ្ញុំសូមស្លាប់ផង
កុំដជាគ្នា ៗ　　នាងទួញអន្ទាស់　　អន្ទងប្រាណប្រាស់

គគក់ទឹក អស់ស្រីស្រីង្គា បរិពារត្រៀបត្រា
ទួញទៅព្រះមហា ក្សត្រក្សាន្តធិបតី ៗ សូស័ព្ទរំពង
ទ្រហោរយំកង សឹងស្ងូរសៀងស្រី ទោះទាំងសេនា
យោធាមន្ត្រី សោកព្រះបក្រី អួលអន់ផ្សឹងផ្សា ៗ
ឯក្សត្រយក្ខយុង នូវព្រះពុទ្ធពង្ស ពន្ទុកសាស្តា
ទ្រង់កន្សែងសល់ ទួញទល់ទុក្ខា ឧបបាទបីតា
ទូលដាក់សិរសី ៗ កាលនោះជិនី ប្រសើរស្រស់ស្រី
រឹងអួលអាឡៃ ប្រហស្បប្រា៉ បុត្រាដៀសដៃ
សន្ទប់លង់ក្រៃ តាំងពីរអង្គា ៗ ក្សិណាក្សត្រយក្ខយល់
នាងនាថនិមល នូវរាជបុត្រា សន្ទប់ឆ្ពោះនៃ
កិតក័យមហិមា យកព្រះគង្គា ក្សង់ក្សិតព្រះភក្ត្រ ៗ
នាងខំដម្រង់ ព្រះស្មារតីគង់ ប្រាណប្រែក្សាក្សាក់
តាំងទិវសថ្ងៃ ប្រពៃវល័គណ៍ ព្រះនេត្រសស្រាក់
ស្រក់ស្រោចភក្ត្រា ៗ យើងនៅស្រដី ឯអគ្គអាសុរី
ជាព្រះបីតា ឲ្យហៅអាមាត្យ ព្រះបាទក្សត្រា
បន្ទូលត្រាស់ថា ហៃអាមាត្យគាយ ៗ ចូលព្រះស្តង់ទៅ
ទូលពីព្រះចៅ ជន្ទង់ឯនាយ ឲ្យស្ដេចបានដឹង
ដំណឹងទាំងឡាយ ថាបុត្រឯអាយ ក្សៃព្រះជន្មជាតិ ៗ
ក្សិណ្ណោះសេណី ស្ដាប់ព្រះធិបតី ក្រញូំក្រាបក្រោមបាទ

ថ្វាយបង្គំលា យាត្រាខ្វាញ់ឃ្មាត រួតរឹងស្ងាត
ទាំងយប់ទាំងថ្ងៃ ៗ កាលក្រោយនោះណា ហេតុបារមីតា
ពន្ស្រពុទ្ធញាណញោយ រំជួលសក្កោ ទេវេឥន្ទថ្ងៃ
បើកទិព្វចក្ខុរៃ យុងយល់ក្សត្រា ៗ កាលនោះព្រះបាទ
ព្រះឥន្ទទនាថ សក្កោទេវ បរបុះបាកបាន
គិមានសួគ៌ា ដល់ព្រះពន្ទ្វា ពុំលុងឡើយហោង ៗ
ផ្ទួចទឹកកន្ទី ប្រស់ព្រះភូមី ដៃដេតប្បុះប្បុង
ប្រែប្រាណក្សាក្សាក់ រកកាលនោះហោង លើកកទាំងសង
បង្គំឥន្ទ្រា ៗ កាលនោះព្រះឥន្ទ ហោមហៅនរិន្ទ
វិលរឹងសួគ៌ា ឯវរក្សត្រី ពិសីសោកា
ទបព្រះបាទា កិលាបលុងក្លាត់ ៗ ឯព្រះភូមី
អរទបប្អូនស្រី នូវរាជបុត្ររតន៍ រីស្ដេចយក្ស
ក្សត្រាបក្រព័ត្រ សឹងត្រេកអរក្លាត់ នឹងបុត្រប្រសា ៗ
ទាំង ៤ ព្រះអង្គ កិលាបទូញទ្រង់ កន្សែងសោកា
អាណាគតអាណិត ពន្ទឹកក្លាត់ណា ហាក់ទុក្ខពីគ្រា
មុះដ្បិតអរក្រែ ៗ មន្ត្រីសេនា សុំស្ទឹតស្នេហា
អរឯងទំនៃ ទោះទាំងព្រះកិ លៀងក្ដីអរក្រ
អរដ្បិតក្សត្រថ្ងៃ រស់រូបជន្ទា ៗ កាលនោះព្រះអង្គ
បន្ទោរសោកបង់ ក្សណាទើបដោយក្សា លើកកវិន្ទ

ស្វាមីនាងណា　ទូលពីអាតីតា　កាលនាងជាកបរ ៗ
សព្វគ្រប់ឥតខ្វះ　កាលនោះទើបព្រះ　ដៃដេតក្ងួរ
បើកបន្ទូលទៅ　ដោយនូវស្មោះស　លួងលោមអង្វរ
ព្រះប្អូនពុំងា ៗ　ប្អូនឆ្លើយអញបង　ខាតខុសឆ្គាំឆ្គង
កាលមុនមិញណា　សូមប្អូនកល្យាណ　មេមានមេត្តា
អាចអត់ទោសា　កុំមេមាសខ្ញាល់ ៗ　មាសបងៗ ឆ្ងាយ ៗ
ជ្រិតបងដោយ　ពាក្យពេចន៍អម្រាល　អស់ពីទូលទៀង
លំអៀងឲ្យខ្ញាល់　បងសូមលាកាល　ទោសទាំងនោះណា ៗ
នាងស្ដាប់ព្រះបង　លើកកទាំងសង　ថ្វាយវន្ទា
ប្រណម្យទូលទៅ　ចោមចៅភពា　កុំព្រួយទេយ្យា
ត្រង់ឯប្អូនស្រី ៗ　ខ្ញុំពុំចងចិត្ត　បរបើកក្រៅក្រិត្យ
ស្រាលស្រើបអប្រើ　ទោះព្រះបាទបង　ឆ្គាំឆ្គងសេចក្ដី
ម្ដេចក៏ប្អូនស្រី　មិនបងវាំទុក ៗ　ទោះបីជីតា
ប្រាំពីរអង្គា　វៀនភបទៅមុខ　ខ្ញុំសោកពុំគិត
តបតឧឡុក　ចិត្តបងបានសុខ　ស្នាលស្និតនឹងគ្នា ៗ
ទាំងនេះហេតុកម្ម　ពីព្រេងបងចាំ　ជិតដោយអាត្មា
ខ្ញុំពុំចងពៀរ　បុំនៀវេក　ឈ្មោះហើយនឹងជា
ពៀរពុំរលង ៗ　ស្ដេចស្ដាប់នាងនាថ　ក្សិនព្រះចោមជាតិ
បើកបន្ទូលស្នង　ប្អូនឆ្លើយប្អូនគិត　គំនិតនេះហោង

តាមដោយគន្ធ ព្រះអង្គទេសនា ៗ ក្សត្រាក្សត្រី
ស្ដាលស្ងួនស្រដី ទៅមកកាន់គ្នា ក្បិនក្រុងអាសុរិន
ភូមិនរាជា អញ្ជើញផងគា វិលវិញរាជស្ថាន ៗ
ហើយប្រើសេនា ទៅទូលក្សត្រា ធម្មិកប្រធាន
នូវនាងសច្ចា ជាយាកល្យាណា ដ្បិតរាជបុត្រមាន
ព្រះជន្មវិញហោង ៗ ឲ្យស្ដេចយាត្រា តាំងពីរអង្គា
ចូលមកនេះម្ដង ដ្បិតយើងនឹងការ រៀបការបុត្របង
ជាច្នើទៀតហោង កុំលែងឡើយណា ៗ

## បទបន្ទោលកាក

កាលនោះអាមាត្យ បង្គំក្រាបបាទលុតលា
កុំផ្សងឡើយណា រលះរលាំងទៅឋាន ៗ
តាំងថ្ងៃតាំងយប់ កុំបានឈរឈប់សំរាន
ក្រែងយូរកុំបាន ដល់ដូចព្រះរាជអាជ្ញា ៗ
នេះនៃនិទាន យើងនឹងបង្ហាញសិនរា
យើងនឹងចរចា ដំណាលដំណើរពិតពី ៗ
ធម្មិករាជា នូវនាងសច្ចាទេវី
ស្ដេចគង់បូរី ជាទុក្ខអប់ផ្សុកកុំក្សាន ៗ
គិតរាជបុត្រា នូវបុត្រប្រសាកល្យាណ
ហេតុម្ដេចកុំមាន ដំនួចដំណឹងឡើយណា ៗ

បើបានទៅដល់ នាយនោះបានយល់មុខគ្នា

ឬម្ដេចយើងជា ទុក្ខតែងទន្ទឹងឯកាយ ៗ

ទុក្ខនសាបសង់ សារើយបាបង់យើងឆ្ងាយ

យើងគិតយើងស្ដាយ មមើមមាញឹកក្រៃ ៗ

កាលនោះសេនា កាន់ព្រះអាជ្ញាមុនវៃ

ត្រូវតែដល់ញ្ញ កុំលុងបរចូលទៅឋាន ៗ

ក្រាបទូលព្រះបាទ ព្រះបរមនាដប្រធាន

ពជបុត្តកល្យាណ ស្ដេចសោយព្រះវិលាលយ័ ៗ

ជ្រិតក្សត្រិយក្យា ស្ដេចឲ្យឡើងប្រាសាទថ្ងៃ

ខ្ពស់ឆ្ងាយពេកក្រៃ ពុំអាចទល់ទប់ផន្ទា ៗ

ស្ដេចស្ដាប់ទូលការ ហេតុជ្រិតសង្រាបុត្រក្យា

ក្ដៅអស់ទ៉ា ហាក់ដូចរគ្គូដូលដេះ ៗ

ទុក្ខទុក្ខម សន្ធចាកចោលលំនៅនេះ

បាបអ្វីដល់ម្ល៉េះ ប្រទះនៅក្ដីមរណា ៗ

យើងពីរចាស់ហើយ ព្រលឹងឆ្ងាយអើយមានបា

ស្មើថ្ងៃមទ័យ្យា បណ្ដូលបណ្ដោចសព្វថ្ងៃ ៗ

បន្ទំរត់ សំបូណ៌សម្បត្តិផ្ទៃ

ព្រមឲ្យមាសថ្ងៃ គ្រប់តែងពិភាក់រក្យា ៗ

នេះម្ដងឥតបើ បាបុត្រហើយតើនរណា

នឹងគ្រងប្រជា    រាស្ត្ររាជសម្បត្តិនេះនៃ ។
ឲ្យអស់បរិពារ    ស្នំស្និទ្ធស្រីស្គាក្រាស់ក្រៃ
គង់គាល់សព្វថ្ងៃ    អនេកអនន្តគណនា ។
ម្ដេចសួនឧត្ដម    បរហាកហោលពុំស្នេហា
ហោលតាំងបីតា    ឬពិតពុំលង់ឡើយហោង ។
ឧប្រាជ្ញប្រាសាទ    ប្រសើរស្អាងស្អាតឥតហ្មង
តាំងស្វេតច្ឆត្រផង    ត្រសុំត្រសាយឆាយា ។
វែនទេពបន្ទំ    ពួកព្រដៀមព្រំមាលា
ខ្ពល់ខ្ពើយសន្ធ្យា    សម្រុងសម្រាន្តនេះនូវ ។
តែកូនរូបរត់    ម្ដេចឡើយបង់បាត់ទេទៅ
ម្ដាយទួញម្ដាយហៅ    សោះសូន្យពុំយល់មុខបា ។
ឧមុខមន្ត្រី    សេនាសេនីយយោធា
អត់ពីបុណ្យប្រា    អំពើអំពល់ពុំក្រាន្ត ។
ឧស្សូនបំណាច់    ភ្ជាប់រៀបប្រដាប់ស្អាងប្រាន
ឡើងគាល់យ៉ៅម៉ាន    សម្ដេចព្រះវរបិតា ។
នេះម្ដងខានយល់    មុខមាសនិមលហើយណា
រាប់ថ្ងៃរាប់ថ្ងា    អាសាសូន្យសោះហើយហោង ។
បំណាច់កើតមមក    ជាបុត្រពន្លកស្នេស្នង
វែងបាននៅសង    គុណយើងតបក៏សមក្ស័យ ។

ខេះពេញអស្ចារ្យ ឥតកល់ឥតការពេកក្រៃ
ទុកខ្មោចមាសថ្ងៃ ឲ្យយើងលើកសព្វសន្ធា ៗ
ស្តេចទួញបណ្តើរ ក្បិនក្សត្រប្រសើរត្រាស់ថា
ឲ្យរៀបយោធា ដ្បិតស្តេចនឹងត្រេចចរផ្គង
សុំស្និទ្ធស្នេហា គគក់ទុករ៉ាយំកង
ស័ព្ទសៀងរំពង អាឡោះអាឡៃក្សត្រា ៗ
ឯអស់អាមាត្យ យុំហើយទូលបាទលុតលា
កាន់ព្រះអាជ្ញា ប្រាមប្រាប់បង្គាប់ពលផង ៗ
ថារ៉ុយគ្នាយើង រួសរ៉ាឆាប់ឡើងជាមួង
រៀបរេហ៍ពលផង ដ្បិតស្តេចនឹងចរយាត្រា ៗ
ពពួកពលនាយ រួសរៀបប្រញាយផងគ្នា
រៀបរួចហើយណា ចូលទូលព្រះបាទនរបតី ៗ
កាលណោះព្រះអង្គ ជ្រាបហើយពុំលង់ឆាប់ខ្មី
នាំនាងក្សត្រី វរវង្សគង់គុជ្ឈន្ទ្រា ៗ
ពលពាលខ្នាន់ខ្នាប់ បង្អៀតអឹងអាប់កស្សា
តាមហែពជា ដង្គុំដង្គោលខ្វលខ្មោ ៗ
ស្តេចចរបណ្តើរ ព្រះនេត្រមៀងមើលទតទៅ
សាយសព្វស្ថានក្រៅ ស្រយាកស្រយាលអគ្គា ៗ
ទតទីទតទួល អាក់អន់ក្សឹកក្សួលក្តាត់ណា

ព្រះឥសូរទូញថា ឱស្ងួនកំសត់ក្សាប្រី ៗ
ស្ងួនអើយឪពុក សង្រេងរងទុក្ខច្រើនក្តី
មួយគិតប្រណី ទូរំនាងស្រីសុវណ្ណា ៗ
សំដាមេម៉ាយ ឯកឯងនៅនាយកំព្រា
ព្រាត់ព្រះមាតា បីតាទូវរាជស្វាមី ៗ
មួយឪពុកគិត អួលអន់អាណិតក្សាប្រី
ជនគោពីសី សោតក្រេងពុំដឹងទុក្ខា ៗ
ប្រាស់ព្រះជិនុក ម្ទេះសំទុលទុក្ខសោកា
កូនអើយអញអា ពុកគិតអាណិតណាស់នៃ ៗ
ឯព្រះជិនី សឹងសោយសោកកិលាពក្រៃ
ល្អោះល្អោបចហុទ័យ ស្រងាត់ស្រងល់អគ្គា ៗ
ក៏រណ្ណោះរាជទូត មួយក្រោយខំស្រូតយាត្រា
តើបពះសេនា ប្រាមប្រាប់ដំណើរកិច្ចគល់ ៗ
ឯអស់មន្ត្រី អរឯងឃ្លាតខ្ចីនាំដល់
ទូលព្រះទសពល សូមទានស្តេចទ្រង់ករុណា ៗ
ដ្បិតមានរាជសារ ព្រះរាជឱង្ការយកក្សា
ឲ្យមកទូលថា ដំណើរព្រះរាជបុត្រថ្លៃ ៗ
ស្តេចមានព្រះជន្ម រស់រួចដោយបុណ្យទិព្វក្រៃ
កុំព្រួយព្រះទ័យ សូមស្តេចកំសាន្តសោក្កា ៗ

មួយសោតយក្ខយស    មានព្រះដម្រាស់ផ្តាំថា
ឲ្យចំយាត្រា    ត្រេចទៅកំផ្សងយូរលន់ ។
ដ្បិតនឹងតែងការ    បុត្រត្នសង្គ្រាឲ្យគង់
នឹងនាងវរវង្ស    មិត្តមួលជួបចូលស្នេហា ។
ស្តែងស្តេចស្តាប់ជាក់    ត្រីប្រែព្រះក្រ្តមីម្នា
អវឯងមហិមា    ស្រាកស្រាលស្រយាលទុក្ខកែ ។
ស្តេចទៀនសេនា    ឲ្យចំយាត្រាវៃៗ
ដ្បិតស្តេចអាទៃ្យ    សម្តេចព្រះរាជបុត្រា ។
ពុំមានឈរឈប់    សឹងលុះត្រឡប់សុរិយា
ទេទាបបច្ចិមា    ស្រទន់ទៀងទាបព្រះព្រៃ ។
បតឈប់សម្រាន្ត    លុះព្រឹកឡើងបានបរញ
ច្រើនយប់ច្រើនថ្ងៃ    ព្រួយប្រាណក៏បានដល់ឆ្ងាយ ។
ប្រពូនប្រពាន់    ខ្វះដើរមិនទាន់ឃ្លាតឆ្ងាយ
អស់ដើររពាយ    ខ្ញីឃ្លាតសង្ហាតបេបរ ។
លុះបានដល់ក្នុង    វែខត្រខណ្ឌកំលុងព្រះនគរ
សឹងហុនបវរ    ព្រះអង្គឲ្យសង់ព្រះពន្លា ។
ទើបស្តេចឡើងគង់    ទាំងពីរព្រះអង្គហើយណា
ត្រាស់ឲ្យយោធា    ទៅទូលតស៊ូព្រះនគរ ។
កាលណោះអាមាត្យ    បង្គំក្រាបបាទកូធរ

លីលាចូលបរ　ដល់ដួចព្រះរាជអាជ្ញា　ៗ
ស្រេចចូលទៅទូល　ក្សត្រថ្ងៃឥសូរយក្ស
ស្ដេចជ្រាបហើយណា　ទ្រង់ព្រះអំណរអរក្រៃ　ៗ

(បទកាក)

ទើបស្ដេចឲ្យទៅ　ទូលបុត្តចោមចៅ　ទឹងជនគោថ្ងៃ
ពីព្រះភូមិន្ទ　ធិបតិនជៀសដៃ　ពីព្រះហឫទ័យ
ឥតឯទេប្បមា　ៗ　កាល្ហោះភូបាល　ត្រកូលត្រកាល
ពូជពង្សព្រុទ្ធា　ស្ដេចពុំផ្សេងផ្សូ　ទៅទូលមាតា
ពីព្រះអយ្យកា　អយ្យកោទសពល　ៗ　នាងត្រេកអរក្ដាត់
ទឹងពីរពង្សក្សត្រ　ស្ដេចស្ដែងមកដល់　ព្រះឱស្ឋស្នូរសា
កុមារទិមល　នាងនាថចង់យល់　ពីព្រះរាជា　ៗ
ក្សិនចិរស់ថ្ងៃ　អ្នកវិលវិលញ　ព្រះវរបិតា
ហើយយាត្រាថ្កាន　ទៅស្ថានអាសុរ　ទាំងព្រះបិតា
ស្ដេចត្រេចទៅផង　ៗ　ស្ដេចចូលទៅគាល់　ក្សត្រយក្ខទ្រង់ធម៌
បើកបទុលស្នង　ដៃដេតអើយបា　អ្នកជាដនួង
ស្ដេចមកហើយហោង　នូវក្រៅសេមា　ៗ　ឥឡូវនេះនៃ
ចូលបាឃ្លាតខ្ចី　ទៅទូលក្សត្រា　នាំរាជបុត្រថ្ងៃ
ប្រៃព្រះសោភា　ទៅថ្វាយវន្ទា　ពីព្រះនរប្បតី　ៗ
កាលណោះព្រះបាទ　ដៃដេតននាដ　ថ្វាយវរវន្ទី

ហើយស្តេចក្រាបលា បីតាអាសុរី នាំបុត្តពិសី
ចុះចាកពេជ្ររតន៍ ៗ ដល់ព្រះពន្លា ប្រដាប់អាត្មា
ពីព្រះអគ្គក្សត្រី ឡើងរាជយាន ថ្កើងថ្កានល្អក្តាត់
លេលាចេញថ្វាត់ ទូវអស់យោធា ៗ ឯពីព្រះអគ្គ
យល់បុត្រវរវង្ស ទូវឱរសា គឺព្រះជនេត្តា
សេថ្ងាឧត្តឡ ស្តេចអរប្រាំ ឱបអង្អែលអង្គ ៗ
បបោសបបក់ ព្រលឹងនៃអ្នក មាសមិត្តឲ្យគង់
លើទិភារត ពីក្សត្រិសុរវង្ស ថ្នមបើបព្រះពង្ស
ពោធិសត្វថ្ងៃ ៗ ហើយបន្ទូលថា ហៃស្ងួនពុំងា
ពន្ទុកថ្ងើមថ្ងៃ យើងនេះតែងជា ទុក្ខមហាទុក្ខក្រៃ
ក្រោយមាសមិត្តថ្ងៃ ចរត្រេបឃ្មាតឃ្មា ៗ កាលបាសំកត
ពេលនោះជួនយប់ យើងពុំដឹងជា នាងនាថឈឺផ្ទៃ
ឡើយនៃណាបា ដឹងតែអស់រ៉ា ប្រាំពីរនោះហោង ៗ
អស់អាថ៌សេចក្រេប អំពើម្តេច ៗ យើងពុំដឹងផង
លុះឪពុកបា លីលាមកផ្គង ទើបទូលទំនង
ដំណើរម្តាយបា ៗ យើងស្រាប់តែក្បាក់ ដឹងដំណើរជាក់
ស្រវត់ម្នា រកពេញមណ្ឌល ពុំយល់ជិតា
យើងពីរយាត្រា ចរចេញទៅផង ៗ តត្រុករុករាន
អស់ចិត្តពុំបាន ឃើញដូចបំណង យល់តែហាបជាក់

ដែលដាក់បាហោង ស្ងួនមីយើងវេង ទុក្ខទួញសោកា ។
ឥឡូវនាងស្រី កូនស្ងួនប្រិមប្រិយ តើនៅឯណា
សុខសប្បាយឬ អង្គឹនូវជា ប្រាប់យើងស្រួរ៉
សោះថែថប់ក្រៃ ។ ទោះតាំងក្សត្រយក្ស រឹងរិទ្ធិសក្តិ
គុណគាប់ប្រពៃ សុខកល់កាយោ មនោហឫទ័យ
ឬម្តេចមាសថ្លៃ ថ្លែងប្រាប់យើងផង ។ រាជបុត្តជនេត្តា
ក្រួញក្រាបសំពេ ប្រណម្យទូលស្នង ក្សត្រីឯកាយ
សប្បាយឥតហ្មង ប្រើខ្ញុំមកផ្គង ទទួលរាជា ។
ឲ្យអញ្ជើញចរ ចូរក្នុងនគរ កំលុងឡើយណា
ស្តេចមានហឫទ័យ អរក្រៃមហិមា ដ្បិតបានយាត្រា
មកដល់ដូចប៉ង ។ ស្តេចទូលគ្រាន់គ្រប់ ដោយដំណើរសព្វ
ពុំធ្វេសឡើយហោង អយ្យកោអយ្យកា ស្នេហាស្ងួនគ្រង
ថ្នមមិនឲ្យហ្មង ព្រះ[illegible]រាជា ។ ស្តែងស្តេចដល់ឋាន
ចុះជាករាជយាន យានយាសយាត្រា ឡើងដល់ប្រាសាទ
ព្រះបាទយក្សា ឲ្យរៀបក្រឡា គុំនាល់រោងរត្ន ។
ស្តេចគង់ស្តេចថ្វាយ បង្គំករកាយ ប្រួញប្រាណប្រណិបត្តិ
ក្សត្រយក្ខសាទរ ត្រេកអរពេកក្តាត់ ស្តេចបន្ទូលថ្វាត់
រោះរាយបរបា ។ សំណោះស្ងួនសង នឹងក្សត្រកន្ទង
ត្រេកសោមនស្សា រីករាយទទួល ស្រាកស្រួលទេយ្យា

ក្សិណ្ណាះយក្សា    ត្រាស់ប្រើទាសី ៗ    រួតរត់ម្ចីមា
អញ្ជើញធីតា    ប្រសើរស្រស់ស្រី    ផ្ងៀតព្រះបិតា
មាតាទេវី    ស្ដេចមកដល់គី    មានមូលនៅគ្នា ៗ
ឯអគ្គក្សត្រី    ប្រសើរស្រស់ស្រី    ជ្រាបដូរឈ្មោះណា
ម្ចីមាពុំចង់    ឲ្យយូរឡើយណា    បរត្រេបលីលា
ឡើងលើពេនរត ៗ    នាងយល់ព្រះអគ្គ    តាំងពីរមកគង់
នាងក្រាបប្រតិបត្តិ    ក្រោមព្រះបាទា    នោះណាក្សិណក្សត្រ
អរទិបបុត្ររត    ថើបថៃកត្រា ៗ    ទ្រង់ព្រះកន្សែង
ខ្សឹកខ្សួលថ្ងូនថ្ងួន    អាណិតអាណា    អាណាត់អាណោក
ពន់ពេកមហិមា    នាងសុវណ្ណា    សោតសឹងសោកក្រៃ ៗ
ហើយនាងដំណាល    ទួញទូលពីកាល    បរចេញមកខ្ញុំ
កាលអស់ធីតា    មោហាគាបក្រៃ    ដោយដំណើរនៃ
ពុំលាក់ឡើយណា    ពីដើមដល់ចុង    ទូលក្សត្រពីរពង្ស
អស់ឥតសង្កា    ជនុកជនី    ក្សត្រិក្សត្រា
សោយសោកថ្ងូនថា    ឱកូនកល្យាណា ៗ    កូនទើយកាលមេ
បាកចេញទូរ    យើងពីរពុំបាន    ដឹងដំណើរនោះ
សូន្យសោះមិនមាន    អ្នកណាទឹងហ៊ាន    ទូលទេមាសថ្លៃ ៗ
ម្ដាយឲ្យគេទៅ    សួរនាងកូនពៅ    ក្រែងមេឈឺផ្ដៃ
គេមកប្រាប់ថា    នាងផាទេនៃ    លុងលុះព្រះដៃ

ដេតមុះមកដល់ ៗ ម្ដាយស្រាប់តែភ្ញាក់ ថានាងចេញចាក
សឹងសោកាណាស់ ម្ដាយឲ្យរត់រក សព្វព្រែកពុំយល់
ម្ដាយចរចេញដល់ ព្រៃព្រឹក្សអព្ភា ៗ ទៅឃើញសំពត់
ថ្មី ៗ ទាំងផ្ទត់ ក្នុងហិបនោះណា ម្ដាយស្ទួរដាក់ស្បាន
សុវណ្ណចំប៉ា រុសរៀងមាគា មើលមិនសង្ស័យ ៗ
ហើយនាងនិយាយ សេចក្ដីអធិប្បាយ រឿងមកនោះនែ
ប្រាប់បុត្រប្រសា តាំងាដើមថ្ងៃ អស់ឥតសង្ស័យ
ព្រះរាជចិន្ដា ៗ ក្សត្របីព្រះអង្គ សោយសោកលន់លុង
ហើយព្រះរាជា បន្ទោរស្រោកស្រោល ស្រយាលសោកា
សំណេះបរហា សាសន៍មេត្រី ៗ កាលនោះព្រះបាទ
ធម្មិកនាថ ស្ដេចថ្វាយវន្ទី ទូលក្រុងអាសុរិន
ភូមិនធិបតី សូមទានបក្រី ទ្រង់ព្រះករុណា ៗ
ទោសទាំងនេះម្ដង ជូនណាស់ទូលល្អង ធូលីបាទា
ពុំបេក្សត្រក្សាន ទ្រង់មានមេត្តា ឲ្យគង់នៅជា
ខ្ញុំកាលនេះម្ដង ៗ កាលនោះយក្ខយស ញញឹមត្រេកត្រាស់
បន្ទូលឆ្លើយស្នង ត្រង់នោះកំគិត ព្រួយចិត្តឡើយហោង
យើងពុំមានបង់ ចិត្តក្រេវក្រោធា ៗ តែឥឡូវយល់
ហាក់យើងឆោតសល់ គេនឹងនិន្ទា ថាយើងថ្ងោះថ្លោយ
អាលឲ្យខ្ជីខ្ជា ពុំពិចារណា គិតគូអាយនាយ ៗ

ពីមុនមិញម្ដង　យល់ហើយផ្គង　កើតទោសដល់កាយ
ឥឡូវនឹងឲ្យ　ដល់ដោយចិត្តរាយ　យល់យើងស្រែស្រាយ
ស្រាលស្រើបពុំធ្ងន់ ៗ　ហេតុនោះឲ្យទៅ　អញ្ជើញព្រះពៅ
មកនឹងគិតគន់　បើបង់ផ្គូផ្គាប់　ចូលចាប់ចងពន្ធ
ឲ្យនូវមូលមន់　ទល់ទៀតនោះនៃ ៗ　ស្ដេចជាបិតា
ស្ដេចហ៊ានធានា　ឬទេក្សត្រថ្ងៃ　ក្រែងធ្វើឲ្យធ្លាយ
ក្រែងក្រោយទៅនៃ　ទោសទៀងទាល់ក្បៃ　ពុំលែងឡើយណា ៗ
ធម្និកភូមិន　ស្ដាប់ក្រុងអាសុរិន　ទើបទូលវិញថា
បពិត្រសូមទាន　ស្ដេចមានមេត្តា　ខ្ញុំសូមធានា
ថ្វាយព្រះជនជាតិ ៗ　ក្រែងធ្វើឲ្យផ្គង　ទៀតទៅនឹងល្អង
ធូលីព្រះបាទ　ប្រកាម្ដេចៗ　សូមស្ដេចពិឃាដ
ដ្យូតមុសាវាទ　បង់សច្ចវាចា ៗ　ស្ដេចយក្ខត្រកអរ
ញញឹមសាទរ　ព្រមព្រះចិន្ដា　ឲ្យរៀបរន្ដាប់
ឆាប់ៗម្ចីម្ចា　ផ្សំបុត្រពំងា　មួលមួយព្រះបង់ ៗ
អស់បណ្ដាការ　សព្វគ្រប់ដោយងា　ដូចពីមុនហោង
ស្រេចការហើយណា　ក្សត្រាប្រាស់ប្បង　ស្នែស្និទ្ធស្ងួនគ្រង
នាងនាដទេវី ៗ　ស្ដេចថ្នមអស់អង្គ　ប្អូនមាសវរវង្ស
ព្រះឱស្ឋប្រិមប្រិ　សំណេះប្រាយប្រាប់　រៀបរាប់អំពី
មុនមិញឥតបី　សេសសល់ឡើយណា ៗ　ឯនាងទេវី

លើកកវន្ទី ព្រះរៀមរាជា និយមនិយាយ
ប្រាប់ប្រាយចរចារ ទូលពីកាលគ្រា មុនមកនោះនៃ ។
ក្សត្រពីរអង្គ រួមរាក់ស្នេហា មូលមួយព្រះទ័យ
ស្ងួនគ្រងទិវស ប្រាណប្រុសប្រពៃ គេរកាលណោះនៃ
ព្រះរាជបុត្រា ។ អញ្ជើញព្រះញ្ញ យកោថ្វាថ្ងៃ
នូវនាងសច្ចា ទតអស់ទីស្ថាន ពិមានប្រាង្គប្រា
សាទស្លួគិតទ្រា សានថ្វាយពោធិ ។ ក្សតថ្ងៃប្រសើរ
គយគន់មៀងមើល ហើយព្រះបក្រី ត្រីប្រាណស្ងប់ស្ងៀង
គ្រញែងសិរសី កោតព្រះបារមី រាជទុរស្រ ។
ទតកាលបុព្រិក្ស តាមតែចិត្តទឹក ភស្តុផងនានា
មិនមានឃ្នងឃ្នើស ទាស់ទើសឡើយណា ដូចចិត្តចិន្តា
នឹកនោះឯងហោង ។ កាលនោះឯអង្គ ត្រកូលពូជពង្ស
ពោធិបក្សប្បង លើកព្រះហត្ថា វន្ទាទូលស្នង
ថ្វាយអស់ទ្រព្យផង ច្រើនក្រៃក្តាត់ណា ។ ឲ្យបញ្ជូនចេញ
ផ្ទាល់ផ្ទុកពេញៗ រទេះគុជ្ជា នាំទៅហោមន្ត
ណែនណាន់នានា សុទ្ធទ្រព្យផាផា មែនមានតម្លៃ ។
ហើយស្តេចប្រទាន សេណាទាហាន ហែមកនោះនៃ
ទោះនាយទោះពល ស្កប់ស្កល់ចិត្តក្រៃ បានទ្រព្យថ្ងៃៗ
ត្រកាលក្តាត់ណា ។ តាមតែកំឡាំង ជញ្ជូនយកទាំង

សុវណ្ណចំប៉ា អំពីឃ្មុំធំ ឲ្យខំពល់គ្នា
កោសេយ្យកស្ត្រា ទូរមនីរតន៍ផង ៗ ស្បៃទិព្វប៉ានប៉ាក់
ព្រែព្រំមាសប្រាក់ ចិញ្ចៀនកែវកង ពេញចិត្តអរឯង
ពុំក្រែងឡើយហោង កែវកូលជាម្ដង ផ្ញើបុត្រភរិយា ៗ
លង់តិចព្រះបាទ ធម្មិកននាថ នូវនាងសច្ចា
ស្ដេចទឹកដល់ស្ថាន ពិមានអាត្មា ឡើងទៅក្រាបលា
ក្សត្រយក្ខធិបតី ៗ បពិត្រខ្ញុំទូល ក្សត្រថ្លៃត្រកូល
ចោមចៅចក្រី នឹងសូមក្រាបលា យាត្រាទៅខ្មី
គ្រប់គ្រងបុរី រុំពងរដ្ឋា ៗ ស្ដេចយក្ខយង់ឃ្លង
ស្ដាប់ព្រះជន្ទូន អន្ទូរលោមលា មានព្រះហឫទ័យ
អាៈឡក្ដាត់ណា បន្ទូលត្រាស់ថា នូវពាក្យឥតគ្គង ៗ
ហើយក្សត្រទាំងពីរ អ្នកនឹងចរចេរ ឃ្លាតឃ្លានេះម្ដង
អ្នកកើយយើងគិត អាណិតកន្ទង ទៅហើយមកផ្គង
សួរយើងឯអាយ ៗ ក្សត្រពីរអង្គា ប្រណម្យទូលថា
ពុំគួរចេញឆ្ងាយ ចោលស្ដេចឲ្យនៅ នឹងទៅដល់នាយ
គួរតែនៅអាយ ជាខ្ញុំបាទា ៗ តែជាចប់ក្ដាត់
ចោលរាជសម្បត្តិ នៅក្រស្ដប្រជា ហេតុនោះយើងខ្ញុំ
នឹងសូមក្រាបលារ ផ្ញើបុត្តពុំរ៉ា ទុកនៅនេះហោង ៗ
សូមទានខ្ញុំទៅ ទុកកូនឲ្យនៅ ទោះខុសទោះផ្គង

ពុំបេរក្សត្រា　ករុណានេះមួន　ផ្ញើផ្ទជាតិផង
នូវទឹកក្សត្រា ៗ　ផ្គាំស្រេចពុំលង់　ប្រដាប់ព្រះអង្គ
ឡើងគង់គុជ្ឈា　បើកបរចេញចាក　លះលាក់លីលា
ទាហានអាសា　ហែស្តេចទៅហោង ៗ　ត្រេចរំលងខែ
មួយមិញដល់ហេ　មន្តមិនមានហ្មង　ចុះចាកគុជ្ឈេន
នរេន្ទបង្ហាស់ច្បង　លីលាឡើងផ្គង　មន្ទីធិបតី ៗ
សុំស្មុទ្ទពាសា　ក្រញ្ញកោបវន្ទា　ពីព្រះនរបតី
គង់គាល់ត្រៀបត្រា　សេនាមន្ត្រី　ព្រាហ្មព្រឹទ្ធិកវី
អរអឹងគ្រប់គ្នា ៗ　យើងទឹងដំណាល　ដំណើរកេត្តិកាល
ស្តេចដល់ហើយណា　យើងនូវចាយចែង　ថ្វាថ្វៃងវាចា
ឯអស់ប្រជា　រាស្ត្ររដ្ឋទាំងឡាយ ៗ　បានទ្រព្យប្រពៃ
មែនមានតម្លៃ　យកមកពីនាយ　ល្អៗចំឡែក
ជូនចែកប្រញាយ　ឲ្យឪពុកម្តាយ　ប្រពន្ធកូនចៅ ៗ
អរឯងស្រើបស្រួល　ខ្វះរត់ទទួល　បងប្អូនញាតិផៅ
នាំទ្រព្យជាៗ　ឡើងនាលំនៅ　យកសំពត់អាវ
ស្លៀកពាក់តែងតួ ៗ　បំនួតអួតអាង　ធ្វើឫកឡើងចាង
ហោតុហៅអ្នកជួរ　កែងកោងហត្ថា　ផ្ទះស្រាមមួ
លេងបៀរលេងធួ　តាមតែបិត្តា ៗ　ខ្វះបាស់កោងខ្លួន
សក់ស្កូវសព្រោង　ស្បែកជ្រីវយួយារ　បានទ្រព្យឧត្តម

ពុំសមអាត្មា ស្អាងស្រេចហើយថា ផ្ដាំចាស់នេះម្ដង ៗ
ក្រមុំមេម៉ាយ យល់យើងសំស្ដាយ ចង់ជួបស្នេស្នង
ប្រសិនកាលពាល ស្របាលនោះហោង រត់ជូនស្វាកង
ផ្ដេកផ្ដិតស្នេហា ៗ ទត់ឡូវចាស់ នូវតែរហាស់
គ្រាន់បើជាងវា ដែលនៅកំឡោះ ពុំស្រស់ដូចតា
បើបានធីតា តាអរថយក្រោយ ៗ ខ្លះស្លៀកកស្រ្ដា
ទុកកន្ទុយប្រា បញ្ចើបង់ហោយ ក្រមុំផងមើល
សរសើរដើមដោយ ចាស់បើកគិតឆ្ងោយ ឆ្ពើហាក់កំឡោះ ៗ
គន់ឯអស់ស្រី មុខមាត់ប្រិមប្រិយ បានរំស្យ្រគបដោះ
ផ្អៀងផ្អងអំពើ បញ្ចើកំឡោះ មុខឲ្យស្រណោះ
អាឡៃក្ដាត់ណា ៗ យើងនូវស្រដី មានពាណិជពីរ
រាជគ្រិះសេមា បួលជួញលក់ទិញ ទំនិញនានា
កន្ទគភ ធម្មិកបុរី ៗ វិនាយសំពៅ
ដល់ហើយឡើងទៅ យល់ទ្រព្យពីសី ពេញចិត្តចង់បាន
សងសានស្រដី ដន្តឹងមកខ្វី កាន់អ្នកសេមា ៗ
អ្នកកើយអ្នកស្រុក អ្នកអាសូរលក់ សុវណ្ណចំប៉ា
ទឹងសំពត់សៃ្យ កោសេយ្យកសត្រា ឲ្យយើងទៅព៉ា
ហៃអ្នកនគរ ។ ឯអស់អ្នកស្រុក ព្រមព្រៀងចង់លក់
ឲ្យពាណិជបរ ពាណិជចង់បាន គាប់ពានអំណារ

ញញឹមឯងអរ ឲ្យថ្ងៃវិញទៅ ៗ ហើយពាណិជសឹង
សាកសួរដន្ទឹង ថាចៅអើយចៅ ទ្រព្យនេះត្រកាល
រន្ទាលផ្អិនផ្អៅ បានពីលំនៅ នគរឯណា ៗ
ទៀបទេឬឆ្ងាយ ដើរផ្លូវដល់អាយ អម្បាលទេវ៉
ផ្លូវគោកឬស្ទឹង ព្រៃកបឹងជល្លសា ទៅទឹងគេត្រា
បានឬពុំបាន ៗ នរអ្នកផងឆ្ងើយ ចៅពាណិជអើយ
ទ្រព្យនេះពុំមាន នៅនគរអាយ ឆ្ងាយណាស់ណាកាន
ចៅអើយយើងបាន ពីស្រុកយក្ស ៗ ព្រះបាទសឹងហុន
ស្ដែងស្ដេងមានបុណ្យ គ្រប់គ្រងភាព ស្ដេចមានបុត្រី
ប្រិមប្រីសោភា ឈ្មោះសុវណ្ណា ល្អល្អះឥតគ្គង ៗ
មែនមានចម្ប៉ា រុសពីឧស្សា នាងនោះឯងហោង
ក្សត្រយើងនេះនៃ បុណ្យក្រៃកន្ទង ផ្សប់ផ្សាជួបបង
ពន់ពាក្យស្នេហា ៗ ស្ដេចមានបុត្រប្រុស រត្នាភជឧរស
ទ្រង់ព្រះនាមា ដៃជេតបក្រី នាងស្រីសុវណ្ណា
ជាអគ្គជាយក្ស ស្នួនគ្រងសព្វថ្ងៃ ៗ មានបុត្តពិសេស
ឈ្មោះទ្រាយធំបេស ប្រាណប្រុសប្រពៃ ស្ដេចទ្រង់ព្រះក្សាន្ត
ប្រទានទ្រព្យថ្ងៃ អស់ទាំងនេះនៃ មែនមិនមុសា ៗ
ផ្លូវសោតសឹងឆ្ងាយ ទំរាំដល់នាយ ខែមួយសោតណា
ចៅរើយទឹងទៅ សំពៅគេត្រា ពុំមានជល្លសា

ទេទៅពុំបាន ៗ អស់ពាណិជស្លាប់ ចងចិត្តចាំខ្ជាប់
ទីទៃគ្រប់ប្រាណ រើអស់ទំនិញ លក់ទំនិញស្រេចបាន
ហើយចរចេញថ្កាន វិលក្រុងនាយណា

## បទភុជង្គ

ស្រេចស្រុះចរចុះក្លៀវក្លា ស្រេចស្រាយយុថ្កា
ហើយហូតស្មាចក្ដោង ៗ ព្រះពាយផាត់ផាយយោលយោង
សំពោរសំពោង សំពៅលឿនលន់ ៗ
លិចពៀចលុនលៀចពេកពន់ មេឃមីអ័បអន់
ធុការផ្សងផ្សប់ ៗ ក្រោមាវហាស៍ត្រឡប់
រលកខ្ទ័រខ្ទប់ បោកបែកផ្កាត្រែង ៗ
វិក្ខិរជុំវែង មើលទៅគួរស្ញែង
ទឹកពជពល្ហសា ៗ រំលង់កោះផង់ត្រៀបត្រា
សឹងថ្មសិលា ជុះដោយជ្រោយនៅ ៗ
នាយកេត្រាវស្រែកហាហៅ កូនខ្វយឲ្យទៅ
ប្រយ័ត្នគ្រប់អង្គ ៗ ខ្សែហូតបង្កូតតែងទង់
ត្រីវិសផ្ទង់ ដោយទ្វអាត្មា ៗ
បើកស្បូតរិះរូតក្ដាត់ណា ប្រាំពីរទេរ៉
ពុំឈប់សម្រាន្ត ៗ ត្រដឹងស្ទឹមស្ទឹងឈរឈាន
លឿនលន់លុះបាន ដល់ជ្រោយមួយនៃ ៗ

គាប់ខ្យល់ខ្ទាំងសល់ពេកក្រៃ    អ័ព្ទអស់ផល្ងសៃ

ពុំយល់ទិស្រា ៗ    រលកមីមកពានពា

ខ្ទរខ្ទប់កេត្រា    រញ្ជួយញាប់ញ័រ ៗ

សន្ធឹកពន្ធឹកអស្ចារ្យ    មេឆោមេឆា

ពូនពានក្បិណក្ប័យ ៗ    អស់ឈ្ពឹញយំទ្ពញកិតភ័យ

ញ័រជើងញ័រដៃ    ក្អែកសអាក្រក់ ៗ

ពេបស្បៀបដង្ហើមធ្ពឹតដ្ពក់    មាត់ស្រេញមុខស្លក់

ផ្សាដោយចិនទៅ ៗ    ខ្យល់ខ្ទប់ត្រឡប់សំពៅ

អណ្តែតសាត់ទៅ    ពាកណាសី ៗ    នៃនេះយើងស្ទុះទុកខ្ចឹ

យើងនូវស្រដី    សន្ទុរាផា ៗ

## បទភាក

ស្តេចវង់ទុក្ខទល់    ក្រោយនាងនិមល    បរបាកឃ្លាតឃ្លា

នាងកេស្បណី    មហេសីសោកា    សោតសឹងសោក្កា

សព្វទិនរាត្រី ៗ    ធ្វើបុណ្យឲ្យទាន    ហេតុចិត្តចង់បាន

យល់បុត្តក្ប្រី    កាលយប់មួយណា    ក្សត្រាធិបតី

នូវព្រះមហេសី    ផ្ទុំផ្ទិមនិទ្រា ៗ    ដាស់ទុំស្បាត់សល់

ក្បិននាងនាងយល់    សុបិនសោកា    ហាក់រាងបុត្រី

នាងស្រីចម្បា    ត្រេចមកដល់នា    មណ្ឌលធិបតី ៗ

នាងអរទុនទិប    ថ្នាក់ថ្នមក្រសោប    បុត្តរត្នពិសី

ថែថើបព្រះភក្ត្រ ហើយភ្ញាក់ឡើងខ្ចី ដោយទឹកអាខ្សែ

នាងសោយសោកា ៗ នាងទូលព្រះបាទ ព្រះបរមនាថ

ពីនិមិត្តណា កាលនោះព្រះចៅ ឲ្យហៅហោរា

មកហើយក្សត្រា ប្រាប់ដោយទំនង ៗ ហោរអើយចូរមើល

ឲ្យដឹងដំណើរ និមិត្តនេះហោង តើកាចឬជា

ហោថាតែម្តង សោះថប់កន្ទុង នឹងកូនពុំរា ៗ

ក្សិនហោក្រាបទូល ព្រះបាទឥស្សូរ តាមក្បួនក្សត្រា

សូមទាននិមិត្ត ល្អឥតឧបមា ថ្ងៃនេះឯងណា

នឹងឮពតិមាន ៗ ពីរាជបុត្រី ប្រសើរស្រស់ស្រី

មែនពិតមិនខាន រាជបុត្រឯនាយ សប្បាយក្សេមក្សាន្ត

ជាទេពុំមាន ភ័យកិតឡើយណា ៗ យូរលង់តិចទៅ

បុត្រថ្ងៃនោះកូ នឹងមកវន្ទា ប្រាកដទៀងទេ

ឥតឯមុសា កុំព្រួយចិន្តា ពេកពន់ឡើយហោង ៗ

ស្តេចស្តាប់ហោហើយ ក្សត្រាត្រានត្រើយ អរក្រៃកន្ទុង

ទ្រង់ព្រះរាជទាន ធនធានទ្រព្យផង ពុំលង់ឡើយហោង

រីឯកេត្រា ៗ រសាត់ចូលដល់ ទូវនាមណ្ឌល

សម្តេចរាជា បតស្រេចកាល្ហោះ ប្រានប្រោះយុត្តា

អរឯងគ្រប់គ្នា រស់រូបពីភ័យ ៗ ក្សិននាយកេត្រា

រករៀបបណ្តារ ការផងវៃៗ សឹងទ្រព្យជាៗ ។

សោភាប្រពៃ　សំពត់កោសេយ្យ　កស្ត្រីនាយណា ៗ
យកទាំងសុវណ្ណ　បំប៉ាសោភ័ណ　ដាក់ពានមីម្មា
ហើយនាំឡើងទៅ　ថ្វាយទៅភាព　លុះលើក្រឡា
គំនាល់នោះនែ ៗ　ស្តេចយល់កស្ត្រា　ល្អល្អះសោភា
ទិព្វទេពកោសេយ្យ　នូវបំប៉ាមាស　ឱភាសប្រពៃ
ផ្ទល់ក្នុងព្រះទ័យ　នឹងភពបុប្ផា ៗ　ស្តេចទ្រង់ព្រះចិន
តាដោយភូមិន្ទ　ចាំដាក់ក្តាតណា　បន្ទូលត្រាល
ស្នូរសាទៃពា　ណាដនាយកេត្រា　កាឈ្មោះឯងហោង ៗ
ហៃពាណិជនេះ　បានទ្រព្យល្អម្ល៉េះ　ឲ្យអញនេះម្តង
ទៅបានពីណា　បំប៉ាឥតហ្មង　ចូលទៅប្រាប់ហោង
ឲ្យអញដឹងក ៗ　ពាណិជទិនអគ្គ　វរវន្ទាធ្ងន់
ប្រណម្យទូលថា　ដោយដំណើរមាន　សូមទានបំប៉ា
បានពីនគរ　ហោមទ្ធស្តី ៗ　ហើយនាយសំពៅ
ទូលព្រះហោមទៅ　ដូចយើងថ្ងៃពី　មុនមកជាភ៏ទ
ព្រះបាទភូមី　គិតថាសំស្រើ　បំប៉ាថោងសុវណ្ណ ៗ
ផ្ទល់មួយម្តេចថា　ឈ្មោះសុវណ្ណា　អញសង្ស្រលន់
ក្រែងក្រុងយកក្បុ　មោហាលោបលន់　ស្តេចបង់បំភាន់
ឈ្មោះបំប៉ាថោង ៗ　ហើយហៅដេយ្យ　នាងសុវណ្ណា
ក្មួងឈ្មោះនោះហោង　មិនអ្នកដទៃ　ក្រៅក្រៃនេះម្តង

ឲកូនស្ងួនគ្រង　សំឡាញ់បីតា ៗ　ពីដួចមេប្រាស
ចាកចេញទិពស　យើងពីរអង្គា　យូរលង់ហើយនៃ
ទើបថ្ងៃនេះណា　ដំង់ដើមស្ងួនក្វ　រស់រួចពុំក្បែ ៗ
រីឯជិនី　កេសណីសោកី　នាងសោយសោកក្រៃ
នាងយកបំប៉ា　បូផានោះនៃ　ថើបថៃរដាក់ញ
ព្រះឲពារត ៗ　អួលអន់ខ្វាបផ្កា　គគុកឲក
ទាំងពីរអង្គក្សត្រ　ស្រណើស្រណល់　សឹងទល់ទុក្ខគាត់
ទៅរាជបុត្ររត　ពុំស្បើយឡើយហោង ៗ

## បទព្រហ្មគិត

នេះទូវនិទានពី　ព្រះពោធិសត្វសោភា
នឹងព្រះវរបីតា　អ្នកនៅនឹងក្រុងអាសុរី ៗ
លង់បន្ទិចទៅរា　សុវណ្ណាព្រះជិនី
កាលកំឡុងរាត្រី　នឹករលឹកព្រះមាតា ៗ
នាងនាថសោយសោយុំ　ក្នុងបន្ទំទិត្យថ្ងៃថ្ងា
ទូញទៅព្រះបីតា　រីងក្បែកក្បលអួលអន់អាក់ ៗ
កាលនោះព្រះភូមី　យល់ប្អូនស្រីថៃវិលក្វ
ល្ងង់លោមថ្នមបបក់　ព្រលឹងអ្នកនាងនារី ៗ
ព្រលឹងមាសមិត្តបង　ហេតុម្តេចហោងសោយសោកី
លាបលទពន់កល់ថ្វី　មាសមេប្រាប់នាប់ណាពៅ ៗ

ប្អូនអើយក្រែងអញបង់ ធ្វើឲ្យធ្គងខុសចិត្តពៅ
ប្អូមុខមន្ត្រីនៅ អង្គព្រះវរាជបីតា ។
នាងស្តាប់ព្រះរៀមពក់ នាងអួលអាក់ក្រាបទូលថា
បពិតព្រះរាជា ជាអម្ចាស់លើសិរសី ។
សព្វថ្ងៃប្អូននេះនៅ បានតក់ក្តៅដោយបារមី
ឥតមន្ទិលអ្វី ៗ នឹងប៉ាំងប៉ាក់អាក់ចិន្តា ។
ឱព្រះមាសប្អូនអើយ លាក់អ្វីឡើយប្អូនសោកា
រលឹកព្រះមាតា នឹងព្រះវរបីតានៃ ។
ព្រាត់ប្រាស់ចាកយូរលង់ សំព្រះអង្គសោយសោកក្រៃ
ដរាបចាស់ហើយនៃ រងព្រួយចិត្តគិតប្អូនភ្ងា ។
ស្តេចស្តាប់ព្រះប្អូនស្រី ព្រះភូមីហោមនាងថា
មាសសើយកំនាងជា ទុក្ខទៅព្រះជនីនោះ ។
រៀមបងនឹងធានា នាំយាត្រាត្រេចទៅស្ទោះ
ថ្កានព្រះអង្គពីរនោះ កុំប្អូនមាសមេបារម្ភ ។
លុះស្រាងស្រេចសុរិយា ក្សត្រទ្រហាថ្ងៃឧត្តម
តើនចាកព្រះបន្ទំ ស្តេចឡើងគាល់ព្រះបីតា ។

## បទកាក

កាលនោះព្រះបាទ ស្តេចនាំនាងនាថ ទូវរាជបុត្រា

ដល់ក្រុងអាសុរិន្ទ ភូមិនថ្ងៃថ្វា ប្រណម្យទូលថា
យើងខ្ញុំទាំងពី ៗ នឹងសូមក្រាបលា ទៅទូលបីតា
នូវព្រះជននី ឯក្រុងហេមន្ត សោភ័នកិនី
ហើយហួសអំពី នោះនឹងយាត្រា ៗ ចាកចេញទៅថ្កាន
នគរពារា ណសីសេមា រកពីរព្រះអង្គ
ផ្ចិតបងឃ្មាតឃ្មា យូរហើយសំដា ទុក្ខទៀងក្រោយក្រែ ៗ
សំយូរលង់ក្តាត់ ក្រវីលវីងថ្វាត់ ឆ្ងាយពន់ពេកនៃ
ពុំគួរលះលាក បោលចាកដោះដៃ ដែលមានគុណថ្លៃ
បង្កើតនាងណា ៗ ហេតុនេះទើបខ្ញុំ លាព្រះបរម្ក
ននាថថ្ងៃថ្ងា ទៅដល់ស្រែចស្រាប់ ក្រឡាប់មកជា
ខ្ញុំព្រះបាទា ដូចដើមនោះហោង ៗ កាលនោះយក្សា
ស្តេចត្រាស់វឹងថា នូវពាក្យស្មេស្មង ស្ងួនទើយបើជា
នឹងលាទៅគ្គង សួរស្តេចជូនង ឯនាយនោះណា ៗ
ឱអញអាឡៃ មាសមិត្តថ្ងើមថ្ងៃ ទាំងពីរគ្នា
គឺមុះមិនបាន ឃាត់ឃាំងឡើយណា ផ្ចិតក្សត្រទ្រហោ
ស្តេចទល់ទុក្ខក្រៃ ៗ កូនអើយបើបា ទៅហើយម្ចា
វិលត្រឡប់រៃ ផ្ចិតអញឪពុក រងទុក្ខក្រមក្រែ
សង្រេងសង្រែ ទន្ទឹងផ្លុំបា ៗ ហើយក្សត្រយក្សយុង
ស្តេចឱបអស់អង្គ ពជនុរស្សា នូវពជបុត្រី

ប្រិមប្រិយ៍សោភា ថើបថែបរបោ សាសន៍មេត្រី ។
ផ្ដែផ្ដាំពាក្យពេច សព្វគ្រប់ស្រាបស្រេច ក្យិណាក្សត្រពាំនបី
លាលាតវិលវិញ ចរចេញចុះខ្ចី ឲ្យអស់មន្ត្រី
រៀបពលរេហ៍ផង ។ រៀបស្រេចពុំលង់ ស្ដែនស្ដេចឡើងគង់
លើកដយានហោង ពលពាលយោធា ក្លៀវក្លាអឹងកង
ហែក្សត្រប្យះប្យង គគ្គញខ្ចូលខ្មៅ ។ ក្មេងក្មាត់រំ
ស្រៃឡស្គរធំ សូរសព្ទសន្ធៅ ពួកពលសប្បាយ
ប្រញាយពេញផ្លូវ ស្ដែនស្ដេចយាងទៅ ដល់ព្រៃព្រឹក្សា ។
លង់លុះជាខែ មួយមិញទៀងទេ ដល់ដូចប្រាថ្នា
ស្ដេចឡើងទៅថ្វាយ កកាយវន្ទា ពីព្រះរាជា
អវត្តថ្មមបាន ។ ស្ដេចឪបងនគោ ឯកឧត្ដមោ
ថ្វាក់ថ្នមត្រកង នូវបុត្រពំង៉ា ទ្វេរហាឥតផ្គង
ត្រកត្រាស់សាសន៍ សូរសព្ទសេចក្ដី ។ ក្សត្របីអគ្គា
ទូលពីរាជា ដោយដំណើរពី ដើមដែលយើងថ្វូន
បាយបែងសំដី សព្វគ្រប់ឥតបី ធ្វេសទ្វេរឡើយណា ។
ធម្មិកភូមី នាំនាន់ទេវី នូវនាន់សច្ចា
ព្រមព្រះទ័យអរ សាទរក្ដាត់ណា ទាំង៤រាជា
ក្សេមក្សាន្តសុខសល់ ។ ក្យិណាឯធីតា ប្រាំពីអគ្គា
លុះព្រះស្ដេចដល់ កៃកាទំគិត គន់គិតរបល់

យើងអើយសំដល់ ដនជាតិមនោ ៗ ឲតតបើនឹង
ពំនាក់ពាក់ពឹង ឲ្យជួយការពារ ទុក្ខកើយរឹងព្រួត
ដម្រួតមហិមា សែនសល់គណនា កម្រកក្រៃ ៗ
នាងគិតតែម្ទោះ មុខមាត់ផ្អូមផ្អោះ ដូចខ្មោចវិស័យ
ហើយខំឡើងទៅ គាល់ធម្មិកថ្លៃ ញាំអស់ដើងដៃ
ដូចគ្រុនសោះសា ៗ កាលនោះក្សត្រី ប្រសើរស្រស់ស្រី
នាង.សុវណ្ណា នាងត្រាស់ត្រអាល សួរសាស្នេហា
ផ្តោះរកធីតា ភក់ទាក់ស្រុសភាយ ៗ អស់នាងនោះខំ
អៀនទិនបង្គំ ប្រញ្ញប្រានពីឆ្ងាយ ឯអង្គព្រះបាទ
ននាថពន្រាយ ខ្លាសពេកអម្បាយ ទឹងនាងនោះណា ៗ
ពុំបើកព្រះសូរ មានព្រះបន្ទូល សាសង់វាចា
តែគង់គួនគំ សំងំនៅនា ក្នុងព្រះទេយ្យា
ទឹងពីឃាដបង់ ៗ ហើយស្តេចក្រាបលា មាតាបីតា
នាំនាងវរវង្ស នូវរាជបុត្រា លីលាមកគង់
នាភីមានម៉ង គាល់គាប់ស្ថានស្ថិត ៗ នាងតាំងនោះណា
ហៃរព្រះរាជា ជុំទឹងស្ងំស្ងិត យល់ក្សត្រាហើយអរ
សាទរពេកក្តាត់ គង់គាល់ផ្តេកផ្តិត អង្គុយរៀងគ្នា ៗ
លុះដល់សាយ័ន ហៃហើយទាបទន់ ទៅទិសបច្ចិមា
កាលនោះព្រះបាទ ននាថថ្ងៃថ្ងា ស្តេចចេញក្រឡា

គំនាលភេនរត ៗ អស់ព្រាហ្មនា ៗ ចាចាស់ព្រឹទ្ធា
មន្ត្រីច្រើនក្តាត់ ស្តេចបើកឱក្ការ រុសភាទៅថ្វាត់
ទឹងបួនមហាក្សត្រ កិលៀនភជា ៗ ស្តេចឲ្យធកឆាំង
ចាប់ចងនាងទាំង ប្រាំពីរអង្គា ទើបព្រះបក្រើ
ស្តេចពិចារណា ត្រាស់ដន្តឹងថា ហៃមេតិរថី ៗ
កាលសុវណ្ណា ប្រសូតិបុត្រា កុំលង់ភត្រី
ហើយហាងឲ្យធ្វើ រូបឈើអប្រើ តាងកូនពិសី
ថ្កល់ពានះនោះណា ៗ ឯអង្គបុត្រនោះ យកទៅបញ្ចុស
នូវនិគ្រោធ្លា ពិតដូច្នោះឬ អង្គឹដូបថា
តើគិតនោះគ្នា ប៉ុន្មានចូលផង ៗ កាលអស់ឪពុក
មកទូលបញ្ចុក ឲ្យអញបរង្គង តើអ្នកណាគិត
គំនិតនេះហោង ឲ្យមកលួងលង ឆ្លើយកុំមោសា ៗ
ប្រាំពីរនាងនាថ ព្ទព្រះបោមជាតិ ភិតញៀវអង្គា
ក្នុកស្ងោដូចស្ងាប់ ឪនអាប់គ្រប់គ្នា ខំទូលទៅថា
បពិតបក្រី ៗ មែនពិតច្នោះហោង អស់យើងខំផង
ក្សត់បុត្រពីសី មួយកាលព្រះអង្គ ត្រេបកុងព្រឹកព្រៃ
សឹងគុំទឹតនៃ យើងខំឲ្យទៅ ៗ គិតព្រមទឹងគ្នា
មួយរយទឹងហា សិបសេសទៀតនូវ ពុំបេរព្រះបាទ
ននាថចោមចៅ អត់ទោសទុក្ខទៅ ជាស្រូវស្របុណ្យ ៗ

# បទពំនោល

កាលនោះដៃដេតកជា ប្រាបដូឈ្មោះណា
ស្តេចខ្ញាល់ញ័រដូចអន្ទ្រើន ៗ ត្រាស់ឲ្យអគ្គអាមាត្យមុន
ត្រិះត្រែបប្រើនលន់ ទៅចាប់អស់ពួកសេដ្ឋី ៗ
ទាំង ១០០ ហាសិបនោះក្តី ធ្វើកុំប្រណី
វានោះដល់តិចឡើយណោ ៗ ចាប់ចងឆាក់ចងគ្រប់គា
រួតរឹតអង្គា ប្រវាក់អន្ទាក់ណែនណាន់ ៗ
នាំមកថ្វាយព្រះប្យះប្យង ពុំលន់ឡើយហោង
ស្តេចឲ្យដន្ទឹងម្នីម្នា ៗ ពិតឬដូចនាងឆ្លើយថា
ប្រួលគំនិតគ្នា ប្រាប់មកកុំរកកលដោះ ៗ
ក្បៀនឯអ្នកទោសទាំងអស់ ទូលដោយស្មានស្មោះ
ពិតហោងដូចពាក្យនាងថា ៗ ស្តេចត្រាស់ឲ្យអស់យោធា
នាំចេញម្នីម្នា សម្លាប់បំបាត់ជនជាតិ ៗ
កាលនោះរីឯពេជឃាដ នានាំខ្ញីឃ្លាត
ចាកចេញពីពជសេមា ៗ លុះដល់កណ្តាលអទ្វារ
ស្រេចហើយនាំគ្នា ប្រួតកាប់សម្លាប់ឆាប់វៃ ៗ
រស់រៀលឈាមច្រាលក្រាលក្រៃ ជនជាតិប្រលៃ
ប្រនួចអក្ខិនហាន់ហើយ ៗ ហេតុកម្មចងទាំជាត្រើយ

ពុំរមួលឡើយ　　អាចឲ្យមកយល់ទាន់ហាន់ ៗ
ទាំងនានប្រាំពីរកាចលន់　　សឹងរៃរៀដិបជន
ប្រាបផ្សិតប្រមាទបុត្រា ៗ　　ស្រេចហើយពេជយាដល័លា
ទៅទូលពជា　　ស្តេចផ្ដាប់ក្នុងព្រះហឫទ័យ ៗ

## បទភាកកិតិ

កេរកាលនោះណា　ផ្ដាប់ដល់បុត្រា　ពន្យរពោធិថ្ងៃ
អ្នកមានមេត្តា　ករុណាសត្វក្រៃ　ស្តេចឡើងទៅញ
ព្រះវរបីតា ៗ　ស្តេចថ្វាយបង្គំ　ហើយក្រាបទូលសុំ
អស់ទោចនោះណា　ជិនុកទសពល　ស្តេចធ្វល់ត្រាស់ថា
យើមេ្តចឡើយបា　សូមស័ព្ទបទអ្វី ៗ　ព្រះពន្ធពុទ្ធា
ប្រណាមទូលថា　សូមស្តេចប្រណី ៗ　បើបើកឲ្យទាន
ប្រុសប្រាណជីវ　ខ្ញុំព្ធបជនជី　វិតរស់រួចបាន ៗ
ប្រយោជន៍យកផល　ជាត្រៃយថ្នាក់ថ្នល់　ប្រដូចទូវស្ថាន
ធ្វន៍ផលសាសាយ　ត្រៃយនាយនិព្វាន　ល្វែល្ហើយគេម្រមក្សាន
លែង់ទុក្ខទោសព្រ ៗ　អ្នកកាចកុំគុំ　តាមដោយបារម្ភ
ធម៌ព្រះទេសនា　គួរប៊ប្រោនប្រាស់　លោកលះវេភ
កុំចង់ចិត្តជា　ពោសទៅឡើយហោង ៗ ព្រះវរបីតា
ស្តេចស្ដាប់ព៌ចា　តាមដោយគន្ធន៍　ព្រះទុស្សសន៍ភាន

បើកបានដូចប៉ង ទើបបុត្តស្នងគ្រង បង្គំលុតលា ។
ស្តេចចរចេញពី ដល់ខ្លោចនោះនៃ នូវអស់សេនា
ក្សត្រថ្ងៃថ្កើងបុណ្យ ដំឡើងសរថ្វា ថ្ងៃងប្រសប់អស់កា
យុយល់ថ្កើងក្រៃ ។ សូរស័ព្ទសន្ធប់ ហាក់ហើយនឹងផ្កាប់
ព្រះធរទីនៃ ជួយជនក្សិនបាន ប្រែប្រានពុំខ្សែ
ផាលផាស់ឡើងញ្ញ បង្គំបាទា ។ ព្រះនាយធីបេស
គុណាធូនវិសេស អរឯងគ្រប់គ្នា ខុបខ្ទាបក្រញួក្រាប
ស្រពាប់សិរសា ទាំងមួយរយហា សិបសេសសោតហោង ។
ទាំងនាងបុស្បា ប្រាំពីរអគ្គា រួបរស់ឡើងផង
ក្រាបក្រោមបាទា កុមារប្រុះប្រុង អរព្រះគុណហោង
ឥតឯឧបមា ។ ឯអស់អាមាត្យ យំយល់ព្រះបាទ
ស្ញប់ស្ញែងចេស្តា ព្រួបព្រឹអគ្គឯង ក្រញែងសិរសា
បែរស្តេចលីលា វិលវឹងមកហោង ។ អយ្យកោអយ្យកា
នូវព្រះបីតា មាតាស្នែស្នង សឹងស្ញែងរំថ្លី
បារមីកន្ទង ឥតនរអ្នកផង ណានូវស្មើរដៃ ។
រាជកុមារេ ពិសេសសេដ្ឋា អ្នកនៅសព្វថ្ងៃ
ពុំដែលមានជ្គង សៅហ្មងព្រះទ័យ គេរកាលនោះនៃ
នាងសុវណ្ណា ។ ទូលស្វាមីក្ត្រ ដ្បិតបទអារក្ស
ព្រះជ្រ័យនោះណា ឥឡូវយើងបាន រួមស្ថានស្នែហារ

គួររៀបមណ្ឌា ការកុំបំភ្លេច ៗ កាលនោះស្វាមី
ស្ដាប់ព្រះប្អូនស្រី សម្រួលសម្រេច ប្រាប់អស់សេនា
យោធារំពេច ឲ្យរៀបផ្សិតស្ដេច ទីងគ្រេចបវគ្គង ៗ
ឲ្យបង់សាលា ស្ពានទេពព្រឹក្សា ល្អល្អះឥតហ្មង
រាជមិត្តធត្រូទង រឿនរង់កន្ទុង ផ្កាក្បីសោតហោង
ប្រឹនក្រែក្ដាត់ណា ៗ ទៀនធូកស្រាបាយ អាហារទាំងឡាយ
ពិសេសពិសា ស្រេបហើយព្រះបាទ ស្ដេចបរយាត្រា
តាំងនាងវិឡា សោតសឹងទៅហោង ៗ ស្ដេចដល់ហើយណា
ក្លួនសត្វភាសា ប្រៀងលេងផ្គោះផ្គង ទ្រហ៊ឹងអឹងអ័ប
សៀងសព្ទរំពង ដូរគទ្រឹផង គគ្រេងលេងល្វើយ ៗ
រប៉ាំកំរៀង ស្រេបស្រែកប្រួបប្រៀង ពិរោះដង្ហោយ
ផ្ដោះផ្ដងកាន់គ្នា បរបារឆ្វាស់ឆ្វើយ សប្បាយលំហើយ
ហេតុបុណ្យក្សត្រា ៗ ឲ្យលើកអាហារ ពាសពេញដាសដា
មកថ្វាយបូជា នាងវិឡាឯង តាំងតែនដងស្រា
សែនព្រេនលាងលា បំណាន់នោះណា ៗ ក្សត្រាតាំងបី
ព្រះទិស្នប្រិមប្រិយ៍ អធិដ្ឋានលា បំណាន់នោះស្រេច
សម្ដេចក្សត្រា គង់ព្រះពន្ទា ប្រាំពីររាត្រី ៗ
រួចស្រេចពុំលង់ កាលនោះព្រះអគ្គ ស្ដេចវិលវិងវិញ
គួរគង់រាជស្ថាន កិមានសួស្ដី ដូចពីមុននៃ

ទ្រមគ្បានសុខា ៗ ពស្ត្ររគទាំងឡាយ សឹងសុខសប្បាយ
ដោយបុណ្យក្សត្រា ឥតទុក្ខទោសភ័យ ដល់នៃអាត្មា
សេនីសេនា ប្រើនក្រៃវីវ ៗ កាលនោះជាយា
នាងសុវណ្ណា ឱនអង្គក្រាយតករ ទូលក្សត្រធិបតី
ស្វាមីភូធរ ថ្វាថ្ងៃងអង្វរ នូវពាក្យឥតគ្គង ៗ
បពិតយុវលង់ អញ្ជើញព្រះអង្គ ស្តេចត្រេចទៅហោង
ក្រៃងក្សត្រទេ្វហា ថ្ងៃថ្វាឥតហ្មង ទន្ទឹងកន្ទុង
ទល់ទុក្ខខ្វាបផ្សា ៗ ស្តេចស្តាប់នាងនាថ ទើបព្រះបោមជាតិ
មានបន្ទូលថា ឲ្យរាជទូតទៅ ស្រុកក្រៅនាយណា
ប្រាប់អស់ក្សត្រា ឲ្យចូលមកថ្វាត់ ៗ ហើយរៀបប្រានប្រុង
ដង្ហែព្រះអង្គ ដោយអាប្រយត្ន ស្រេចស្តេចឡើងទៅ
ទូលទៅបោមក្សត្រ ប្រញាប់ប្រាន់ប្រណិបត្តិ មាតាបីតា ៗ
បពិតព្រះអង្គ ទាំងពីរសូមទ្រង់ ព្រះរាជករុណា
យើងខ្ញុំទាំងពី អត្តវន្ទា នឹងសូមក្រាបលា
លាគលះទួរទី ៗ ទៅសួរមាតា ស្ថិតនៅពាក
ណាសីសួស្តី ហើយនឹងត្រឡប់ មកដាប់វង្ខ
សូមព្រះបក្រី បើកបានដូចប៉ង ៗ ពីព្រះកជា
ស្តាប់បុត្តទូលលា នឹងចាកបវង្គង ក្អួលអន់ព្រះទ័យ
អាឡៃក្តាត់ហោង ស្តេចថ្ងមត្រកង ទាំងបីអង្គា ៗ

បើកទាំងតាល់ទៅ ឈឺឆ្អួលក្តាត់ក្តៅ បន្ទូលផ្តាំថា
បើបាទៅហើយ ស្ងួនឡើយបូរបា វិលមកឆាប់ណា
សោះថប់កន្ទួង ៗ កូនឡើយយើងនៅ • សព្វថ្ងៃមានទោ
ទាំងបីស្ងួនស្ងួង ទោះសានទោះសុខ ទោះទុក្ខទោសផង
សង្ឃឹមស្ងួនគ្រង លំហើយហាបុទ័យ ៗ ស្តេចថ្នមជនទោ
គ្រងគង់បីទ្រ ចើបថែហើយនៃ ទ្រង់ព្រះករនៃស្រី
ប៉ុនថ្ងៃនឹងពេកក្រៃ ទាំងបីក្សត្រថ្ងៃ សោតសឹងសោកា ៗ
ស្រេចបរន្ទាបង់ ទាំងបីព្រះអង្គ ថ្វាយបង្គំលា
វិលវិញដល់ស្ថាន វិមានអាត្មា ទ្រង់គ្រឿងក្រស្តា កូសាគ្រប់អង្គ ៗ

## បទពំនោល

កាលនោះអស់ក្នាក់ម៉ាផង រៀបស្រេចហើយហោង
បរិបូណ៌អញ្ជើញក្សត្រា ៗ ទើបព្រះពង្សព្រឹទ្ធសាស្តា
ស្តែងស្តេចលេលាសីហនាថ គគាតចេញចរ ៗ
ឡើងគង់លើរាជអស្សជេរ រូបរាជកេសរ
ហៀវហោះចេញចាកគោហារ ៗ មើលម្តងហាក់អង្គឥន្ទ្រា
ចុះចាកសួគ៌ា ស្រេចស្រុតប្រុតមកហោង ៗ
សេនាយោធាអឹងកង ខ្មាន់ខ្មាប់រំពង
ដគ្គុំដគ្គួលខ្វល់ខ្វាល់ ៗ អស់ស្តេចប្រទេសស្រុកក្រៅ

រៀបរៀងគ្នាទៅ    ដោយពារជំពូកកាសា ៗ
ឯអង្គព្រះវរបីតា    ស្ដេចគង់គុផ្ឆា    ដៃន្ហរជាផ្លូវលំដាប់ ៗ

## បទកាក

ទើបវរក្សត្រី    ប្រសើរស្រស់ស្រី    នាងសុវណ្ណា
ប្រដាប់ព្រះអង្គ    ពំលង់យាត្រា    សុំស្និតស្នេហា
ហែរនាងនារី ៗ    រីព្រះរាជរត    ល្អល្អះពិសុទ្ធ
ពិសេសសួស្ដី    កញ្ចកកញ្ចោង    ព្រាតព្រោងរស្មី
មាសមៃមុនី    ដាលដាំរចនា ៗ    ចន្ទោលសឹងពេជ
ក្បូរក្បាច់រលេច    ជាត្បូងនាគា    មានទង់ដែនដៃ
សឹងចងនៅនា    ចន្ទោលរត្នា    ល្អល្អះសន្ទោ ៗ
នាងឡើងទៅគង់    ព្រហស្ពស្ដាំទ្រង់    ជន្ទញ្ញិនឆ្អៅ
សុវណ្ណចាំរី    ពិសីឥតសៅ    សោតសឹងចន្ទូរ
បុងចន្ទញ្ញណា ៗ    ព្រហស្ពឆ្វេងទ្រង់    កកាន់ទាញទង់
ខសុកពជា    សឹងមាសមណី    សោកីថ្ងៃថ្លា
ទ្យនាងវិទ្យា    និតនៅកន្ទ្យ ៗ    ឯអស់ព្រះស្នំ
អគ្គយាយចាស់ទុំ    អាណែកក្រាស់ក្រៃ    ឡើងដោយជំនិះ
រទេះទីទៃ    ដោយអន្ដាប់នៃ    សក្តិយសធំតូច ៗ
ល្អ ៗ ឧត្ដម    ពាលពេញក្រុំ    បង្កើះរៀវស្ដួច

ដំណើរល្វាសល្វន់ ឈានស្មើតួរូប ញញឹមមានខួប
ឡើងលើរថ្គា ៗ ក្រឡេកមើលទៅ ម៉ត់ហ្មង់ស្រស់
ដូចកូនទេព្ដា ល្អដូចគេស្រិត ប្រិនក្ដាត់មហិមា
ទីង៍គិតគណនា រិះរាប់ពុំបាន ៗ កាលនោះដៃយា

បរពដរត្នា ចរចេញចាកបាន ដូចបូរមីចន្ទ
ចែងស្យាន់ថ្កើងថ្កាន រៀងរស្មីមាន ចាកទីបូពា ៗ
ឯអស់មេទំ ត្រៀបត្រាគុះគំ ដូចកលតរា
ភ្លឺផ្លេកយល់យង់ ត្រចង់ជ្រះថ្លា នៃបទីងចន្ទ្រា
នាទុក្ដាលៃ ៗ នាងត្រេចដាក្រោយ អណ្ដាប់អណ្ដោយ
ពីព្រះដៀសដៃ បបួរបានដល់ មណ្ឌលព្រឹក្សព្រៃ
ខ្ចាន់ខ្ចាប់វិសៃ ពលមានោះណា ៗ ឈើផង់តូចធំ
រគ្គោះរគ្គំ ល្អិតល្អាបសោះសា ក្សត្រទាំងបីអគ្គ
ត្រេចត្រន់យាត្រា បានសត្វទៅ ដល់ឆ្នេរស្រះស្រង់ ៗ
បញ្ជប់អាសុពា គុជ្ជនរត្នា សំបតការង់
ហើយក្សត្រធិបតី ទាំងបីព្រះអគ្គ ស្ដេចទឹងចុះស្រង់ គគ្គាភរ ៗ

## បទបន្ទោលកាក

ស្ដែងស្ដេចយាត្រា យាងដោយមាគាព្រៃភ្នំ
សង្ឃាតវែងទំ លលៀកលលោមក្ដាត់ណា ៗ

ពលពាលទាំងឡាយ ស្រើបស្រួលសប្បាយគ្រប់គ្នា
គេបេះផ្កា បុប្ផានូវផលព្រឹក្សផង ។
ខ្លះទុំខ្លះខ្ចី រុសរោយដោយដីសោតហោង
ខ្លះឡើងរលោង ស្រគុំស្រគាលល្អក្រៃ ។
ខ្លះបេះបានបរ ភោគហើយអួតអរទៃ
ស្រេចហើយវិលវៃ រឹងរូតរឹងស្រួតយាត្រា ។
យូរលន់លន់ក្តាត់ ប្រាំពីរខែស្អាត់ហើយណា
ដល់បុនសោមា ក្រៅក្រុងពាពណាសី ។
ស្តេចបតមួយហាន ប្រាប់អស់តាហានមន្ត្រី
ឲ្យបតអោយទី ហើយស្តេចឲ្យសង់ព្រះពន្លា ។
ស្តេចឡើងទៅគង់ ទាំងបីព្រះអង្គហើយណា
ស្តេចឲ្យយោធា ធ្វើសឹងទង់ផែសរសុទ្ធ ។
ក្រែងអ្នកសោមា ផ្អូកផ្អើលកេយព្រាស្ទុនស្ទុត
ដាលវាលរួតរត់ ខ្វាបសិកសត្រូវនានា ។
កាលនោះអ្នកស្រុក ឃើញផ្អើលតគុកជ្ងុធ្វា
ទន្ទត់តត្កមា ចុះអះពះស្ទាប់ទេះម្តង ។
ខ្លះឈៀងធក់កូន ខ្លះរត់ដញ្ជូនទ្រព្យផង
ព្រាត់ប្អូនព្រាត់បង រយើករយាកយាត្រា ។
ចាស់ៗកោងខ្នង ដោះយោលតែងតោងសោះសា

ខ្វេសខ្វាសប្រាំ　អង្រឹតកញ្ជើទូលទៅ ៗ
ទ្រព្យធននា ៗ　ដោយភ័យក្ដាត់ណាហោលទៅ
ហោលនាំកូនចៅ　រមើករង្គួយដោយផ្លុះ ៗ
ខ្លះស្រែកខ្លះយំ　លើកដៃប្រណម្យសំពះ
បន់ខ្មោចក្នុងផ្ទះ　ឲ្យជួយរក្សាការក្រែង ៗ
ឱ:ឱខ្មោចម៉ែ　ខ្មោចឪពូកស្ដូង ៗ
ជួយកូនខ្លាចក្រែង　ក្បិនក្បត់ឲ្យរនេះណា ៗ
ខ្លះមានស្មារដ៏　ដេថាអាប៉ែខូចណា
មិនបន់ខ្មោចតា　ហើយតើទីងរូបម្ដេចឆ្ងាយ ៗ
ខ្លះថាជួបឆ្កួត　អនេះវាឆោតអប្រាយ
ខ្មោចតាខ្មោចយាយ　វាបន់ប៉ុន្មានដងហើយ ៗ
កាលនោះត្រូវទៅ　ដល់ចៅមឿងក្រោជាក្រើយ
ពុំផ្សផ្សងឡើយ　តែងទពប្រញាប់ម៉ឺម្នា ៗ
សេលោលីតែង　ដាវខ្វីដាវវែងធ្នូស្នា
គ្រប់គ្រឿងសស្ត្រា　អាវុធប្រកិតប្រៀនក្រៃ ៗ
ហើយតាំងដើរល្បាត　ចរចេញសង្ខាតវៃ ៗ
លបល្បួចរំពៃ　មៀងមើលដំណើរសាសិក ៗ
ទៅទៀបទ័ពដៃ　យល់ហើយកិតភ័យភ្ញាំងភ្ញិក
គន់គិតថាសិក　សត្រូវនេះតើនរណា ៗ

ថយក្រោយពុំឲ្យយល់ប្រាន ៗ ហើយវិលទៅប្រាប់
ទៅមឿនមេទ័ពឲ្យប្រាន ដឹងពតិមាន
រិងកិតឯងឥតឧបមា ៗ តែងសាចូលទៅ
ក្រាបទូលចោមចៅពញា ជាម្ចាស់សិរសា
សព្វគ្រប់អស់អាថ៌សេចក្ដី ៗ ទៅរតពុំឈប់
ទាំងថ្ងៃទាំងយប់ឃ្លាតខ្លី ដល់ឯកមន្ត្រី
ប្រាយប្រាប់ដោយដំណើរនោះ ៗ ក្បួនឯសេនា
ដឹងហើយតក្កមាស្មាស្មុះ លាន់មាត់ថាឱ:
ឱសឹកសត្រូវពីឯណា ៗ ហើយខំស្វៀកពាក់
មានស្វាម្ចជាក់ច្នក់ជា ស្វរះបម្លាម្ន
រលះរលាំងចេញចរ ៗ ចូលទូលក្សត្រក្សាន
បពិតដ្បិតមាៈនទៅមក ថាមានសឹកចរ
ចូលមកដល់នាស្រុកក្រៅ ៗ ពលគុជ្ឈពាដី
រត្សរត់សារបីខ្ញលទៅ ដាលដាក់ទ័ពនៅ
ច្រើនក្រៃអាណែកគណនា ៗ បង្អៀតអស់ព្រៃ
គឺមោះទង់ជ័យដោយថា សស្រុតសោភា
យល់ប្លែកទឹងអស់សឹកផង ៗ ឱយើងក្រៃក្រែ

កើតសង្គ្រាមភ័យនេះម្ដង ឥតអ្នកណាហ៊ាន នឹងអាចទប់ទល់ជានា ។

## បទពំនោល

កាលនោះសន្ទុកដក្កុម៏ ក្រាបដោយមន្ត្រី
បក្រីព្រួយព្រះចិន្ដា ។ បារម្ភក្រែងអស់ប្រជា
ពស្ត្រូវគ់ក្រឡា ផ្ទៃក្រោមៈនៅសូន្យអន្តរាយ ។
អ្នកនោះមហិមារិទ្ធិសាយ លើកលុះដល់អាយ
បណ្ដាញបណ្ដាលគោសធំ ។ ទឹបើកូនស្ងួនទុក្ខម
នូវហើយម្ទេះសំ មានប្ដីបេញច្បាំងរឿនរុង ។
ព្រះកាយព្រះពណ្ណាពន្លឺ ព្រះអង្គបិទូរអង្គ
ឲ្យយល់បេស្ដាស្ដែងជាក់ ។ ឥឡូវឥតឯមានអ្នក
ណាទឹងតែងស្លាក់ ដំណែងដំណាងពលក្សរ ។
ទអញចាស់ម្ទេះហើយក្ដី ប្រទះសត្រូវ
មួងហើយនឹងទប់យ៉ាងណា ។ ស្ដេចទ្រង់ព្រះពង់ចិន្ដា
ត្រាស់ឲ្យយោធា លើកចំពប្រញាប់ចេញទៅ ។
តតាំងកាំងស្រុកក្រោ ផនបទលំនៅ
ប្រយោជន៍ប្រយត្នសេមា ។ កាលនោះជ័យដេតរាជា
ស្ដេចគង់ព្រះពន្ទា ហើយត្រាស់ប្រើពួកមន្ត្រី ។

ឲ្យនាំរាជសាស្ត្រី ទៅទូលចក្រី សម្តេចព្រះវរបិតា ។
ផ្តាំឲ្យទូលអាតីតា នាងនាថចំប៉ា
សម្តេចព្រះរាជបុត្រី ។ កាលព្រាត់ខ្ចាយខ្ចាត់ខ្ចួរទ័
ព្រោះផ្សិតគម្ពីរ ទុស្តព្រើសបុស្សាផ្តនា ។
ឥឡូវវិលវ័នយាត្រា នាំបុត្រពំណា
នូវអគ្គសម្តេចស្វាមី ។ ប៉ុនប៉ង់មកថ្វាយវន្ទី
ពីព្រះនរុប្បតី ពិសេសពិសុទ្ធសោភា ។
ឥតអគ្គិសិកនា ៗ មុះមកពាធា
ប្រមាទព្រះបាទឡើយហោង ។ អាមាត្យក្រាបបាទពប់វង់
បរបាកចេញផ្លូង ពុំឈបពុំឈរឡើយនៃ ។
ក្បិនឯកង់ទ័ពនោះខ្វី លើកមកព្រើនក្រៃ
យល់ហើយកិតភ័យរាល់គ្នា ។ ឃើញអាមាត្យដើររោ
ហើយគិតស្មានថា ទ័ពគេលើកមកដល់អាយ ។
ផ្អូកផ្អើលមៀងមើលពីឆ្ងាយ រត់មកប្រញាយ
ស្រៀវស្រែកដណ្តឹងទៅថា ។ វិយ ៗ នៃអស់ទាំងគ្នា
នោះមកពីឯណា ពុកពាទគង្វានដល់អាយ ។
ទើបអស់រាជទូតទាំងឡាយ ប្រាប់ថាអ្នកកាយ

យើងមកពីនាងចំប៉ា ។ ជាបុត្រព្រះរហាក្សត្រា សទុភជា
អម្ចាស់នៃអ្នកនោះហោង ។ កាលនោះអស់អ្នកម៉ែពង
អរក្រៃកន្ទង ផ្សិតឮនាមនាងចំប៉ា ។
ចូលសួរទទួលចរចា ដឹងដើមកាតីកា
ដំណើរទំនងជាក់ស្បាន់ ។ សេនាអរឯងរីខាន់
រតរះរន្ទាន នានាំពជទូតទៅផ្ទាត់ ។
ផ្លូវឆ្ងាយកន្ទុះខែស្ងាត់ ស្រេចដល់ពេងរត
ក៏ចូលបង្គំវន្ទា ។ ទើបទូលដោយដំណើរណា
សទុភជា ស្ដេចអរតេគងង្ហិមបាន ។
ឲ្យទៅទូលនាងកល្យាណា ដោយដំណើរមាន អំពីសម្ដេចបុត្រៗ ។

## បទកាក

កាលនោះមាតា ប្រសើរសោភា នាងកេស្រណី
អរឯងម្ចីមា លីលាឡើងខ្ចី ដល់ហើយវន្ទី
ព្រះរៀមពជា ។ ក្សត្រពីរពន្ទាយ ត្រេកសោមសប្បាយ
ព្រិព្រះកន្ត្រា សោកសោនទុក្ខភ័យ កាលថ្ងៃនោះណា
ឲ្យហៅយោធា វេពលទាំងឡាយ ។ មីមកខ្វាន់ខ្វាប់
ទ្រង់ព្រះបង្គាប់ ទាំងពលទាំងនាយ ឲ្យរៀបនាវា

ម្នីម្នាប្រញាយ ច្រើនក្រៀមកាយ ពាសពេញផលសា ។
ស្ដេចឲ្យចេញទៅ ទទួលបុត្រទ្វ ព្រះពន្ធាថ្ងៃថ្ងា
កាលនោះអាមាត្យ សង្ហាតយាត្រា ច្រើនឥតឧបមា
ដល់ដូចបំណង ។ ឡើងទៅវន្ទា ប្រណម្យទូលថា
ពីព្រះបរុះបរុង ទ្រង់ព្រះអំណរ សារទក្ដាត់ហោង
ប្រើខ្ញុំមកផ្គង អញ្ជើញករុណា ។ ស្ដេចស្ដាប់វរវាត
អស់អគ្គអាមាត្យ ទើបព្រះរាជា ត្រាស់ឲ្យប្រុងប្រៀប
រួសរៀបម្នីម្នា ហើយស្ដេចយាត្រា ទាំង ៣ ព្រះអង្គ ។
ឡើងគង់រាជយាន រង់រៀងជើងថ្កាន ហេតុហៅពុទ្ធពង្ស
សេនីសេនា យោធារៀនរង់ គ្រប់ប្រានប្រៀបប្រុង
ប្រុងប្រាងខ្នាន់ខ្នាប់ ។ ហែវរក្សត្រី ហែព្រះបត្រី
តាមដោយអណ្ដាប់ ហែព្រះរាជបុត្រ ពង្សពុទ្ធគួរគាប់
យោធាស្រួចស្រាប់ ស្ដែងស្ដេចលីលា ។ ដល់ផលសាសាយ
រីព្រះស្រោយ ដីបេសរាជា ស្ដេចពុំពរង់
ឡើងគង់នាវា ក្រុងគ្រុឌបក្ខា ដក់នាគកាងកាន ។
ប្រាសាទកណ្ដាល រចនាត្រកាល សុទ្ធសឹងសុវណ្ណ
ដាំត្បូងរំលេច និលពេជ្រលោ កាន មរកដសោភណ្ឌ

ពិតាននោះណា ៗ គួររូបបក្សី ដណ្តើមចំណី

ផល់ចិកសិរសា មានទាំងរូបគ្រុឌ តយុទ្ធនាគា

យក្សយុទ្ធនឹងស្វា ស្វាតោងកយក្ស ៗ គ្រែសោតប្រាំជាន់

មានរូបកំកណ្ហ ទ្រោលទ្រគ្រប់ថ្នាក់ រូបទេពប្រណម្យ

បន្គដោមដាក់ បំជ្រុងវិយោគក្តិ កាងស្លាបក្រទា ៗ

សម្តេចព្រះរ បីតាភូធរ ជ័យដេតភាជា

ស្តែងស្តេចឡើងគង់ នាកុងនាវា មណ្ឌលសោភា

ទីនាំងរូបមុក ៗ ប្រាសាទមុខដាច់ ឆ្លាក់ឆ្លៀកក្បូរក្បាច់

សុតរូបកិណ្ណ ទន្ទេងរាំ ខះខទ្រោលទ្រ

គ្រែបីជាន់ដ ភីរ៉ល្វីគ្រប់ជ្រុង ៗ ឯអង្គឯកអគ្គ

មហេសីវរលក្ខ ពិសេសវរមង គល់គីមាគា

ពុទ្ធាពូជពង្ស លេលាឡើងគង់ ទីនាំងប្រពៃ ៗ

បតុមុក្ខា ក្រុងកម្ពុជា ភងវៀវលវៃ

រូបទេពអក្សរ ឈរនឈរលើកដៃ ទ្រទ្រែតមាសមៃ

ឆ្លាក់ក្បឹលិបង់ ៗ អស្មានស្មិសិក សៅជ័យរូបរិត

ជាត់ភ័គ្រផូផង់ ញ៉ៀកញ៉ៀក់ញ៉ែងញ៉ៀង ល្ដាយល្អួងត្របង់

ត្របះរស់អង្គ ចុះជិះនាវា ៗ ទូកទ័ពទៅមុន

ត្រៀបត្រាពេកពន់ វៀតាំងនាង ទូកដាក់ក្វេងក្វាត់
ហែរក្សត្រថ្ងៃថ្វា ស្គួយនស្គា ស្រៃឡស្គទេព ៗ
គងតូចគងធំ ប៉ីអរស្នូរសំ ធាប៉ីធឹងចាប់
ស្រៃឡពាតគង ណែនណាន់ស្នូរស័ព្ទ ប្រុងប្រៀបប្រដាប់
ប្រកដោយដៃ ៗ ទូកតូចទូកធំ ពល់ពាលជួបជុំ
មីមកក្រាស់ក្រៃ កាលនោះព្រះបាទ ននាថថ្វាថ្ងៃ
ទួងគីរីដៃ លាន់ឮខ្ចាយខ្ចួ ៗ បីដងស្រាប់ស្រេច
ទីនាំងសម្តេច រាជបុត្រចេញចរ ត្រចះចាំងចែង
ទន្ទេងងើយង កណ្តាលសាគរ ព្រោងព្រាយសន្ធៅ ៗ
បន្ទាប់បុត្រា ព្រះវរបីតា ធិរដបោមបៅ
ទីនាំងវៀលតឹង ល្អផ្សឹងព្រាលល្អៅ ក្លីផ្ទុកមើលទៅ
ចិញ្ចែងព្រោងព្រាយ ៗ ព្រះវរមាតា ក្រុងកម្ពុជា
ល្អល្អះធើតឆាយ ចេញដាលំដាប់ ខ្ទាន់ខ្ទាប់រៀងរាយ
រាស្ត្រផងទាំងឡាយ នូវអស់មន្ត្រី ៗ សម្តេចរាជា
គង់យានយាត្រា ស្តេចទាំងពីរបី រាស្ត្រគេយង់យល់
ស្តេចដល់មកខ្ចី ទោះប្រុសទោះស្រី អរអឹងគ្រប់គ្នា ៗ
ដៃដាក់លើត្បូង សំពះឡើងប្រូង សរសើរចេស្តា

ពុំគួរបើទឹង វិលវង់មុកណា ហេតុបុណ្យដេយ្យា

ប្រសើរក្រាស់ក្រៃ ៗ ឧម្ចាស់បីអង្គ ល្អល្អះត្រចង់

ឥតអ្នកដទៃ ទឹងផ្ទឹមត្រឹមបាន កល្យាណ ល្មមល្មៃ

ហាក់ទេវបុត្រថ្ងៃ ចុះចាកសួគ៌ា ៗ ស្តេចឲ្យអាមាត្យ

ទៅទូលព្រះបាទ ព្រះវរបីតា នូវព្រះដំនី

ក្សត្រីថ្ងៃថ្វា ជ្រាបហើយក្សត្រា ស្តេចត្រេចមកហោង ៗ

ដល់ចុះពុំលង់ ក្សត្របីព្រះអង្គ បង្គំរាប់វង់

ពីព្រះរាជា ប្រាប់ត្រកង់ ថ្នមឧបឥតហ្ន

ទាំងបីអង្គា ៗ ថើបថែរព្រះភ័ក្រ បន្ទូលថាអ្នក

មាសមិត្តពាំង៉ា កាលក្រោយសួនខ្ចាត់ ព្រោយព្រាត់ឃ្លាតឃ្លា

កូនអ្នើយយើងណា ទុក្ខក្រៃកន្ទង់ ៗ

ខ្សែ ៧ សង្ខេបតែប៉ុណ្ណោះ

ខ្សែ ៨ ដើមនាងចំប៉ាថោងទៅលាបំណាន់អ្នកតាដើមជ្រៃ

កណ្តាល ស្តេចទាំង ៧ ព្រះអង្គជិះលើយក្សទៅនគរសិងហុន

ចុង ទ្រាយធំពេះអភិសេកជាមួយនឹងកូនព្រះឥន្ទ្រហើយបានព្រះ

រាជបុត្រ ៩៣ ព្រះអង្គ

(ចប់ត្រឹមខ្សែ ៨)

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេគ្រីន ភ្នំពេញ

ជិតរោងកុន ព្រហ្មបាយ័ន ពីខាងកើតផ្ទាល់

# សេចក្តីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលចងក្របសៀវភៅ មានជាវព្រះពុទ្ធរូប

រូបថតផ្សេងៗ គឺព្រះរូបព្រះករុណា នឹងសម្តេចសង្ឃនាយកជា

សៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សន្សូដិកា ឆាប

កំណើត កាតកូនសិស្ស នឹងសៀវភៅបារាំង-ខ្មែរផ្សេង ៗ ជា

សូមមិត្ត នឹងអញ្ជើញលោកអ្នកចូលជាវវិញ ដោយ

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរស ។

ព.ស. ២៤៩៦ គ.ស. ១៩៥៣

) រោងពុម្ព ភិក-ភ៌ ភ្នំពេញ (

ថ្លៃ ១២៛០០